# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៧ ខែកុម្ភៈ លេខ ២

ព.ស. ២៤៩៧ – គ.ស. ១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង ទំព័រ

*ផ្នែកសាសនា*

— វិហារណកថា .... ......... ពុទ្ធសាសនបណ្ឌិត្យ ....... ៨៣
— អភយទានពិសេស ........... ព្រះឧបាលិវង្ស សួរ-ហាយ ... ៨៧
— បញ្ញាសជាតក ភាគទី ៣ (តមក) .... បណ្ឌិតមហា ឈឹម -ស៊ុម .... ១០២

*ផ្នែកអក្សរសាស្ត្រ*

— រឿងសាមកុក (តមក) ......... ឧកញ៉ា នូ- កន ......... ១១៨
— រឿងបល្ល័ង្កទិព្យ (តមក) ......... លោកភ៉យ- ប៊ុក ........ ១២២
— សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ
បរិយាយពីចំរៀងនឹងប្រយោជន៍ចំរៀង .. លោកវាប - ពិន ........ ១៣១

*កំណត់ទិនប្បវត្តិការណ៍*

— អនុសំវច្ឆរមហាសន្និបាតទី១១នៃមន្ត្រីសង្ឃ
សម្រាប់ឆ្នាំ ១៩៥៥ ...... ...... ពុទ្ធសាសនបណ្ឌិត្យ ....... ១៤៦
— ពិធីបុណ្យទក្ខិណានុប្បទានរបស់ព្រះសា-
សនមុនី មាស-កង ចៅអធិការវត្តពិភពវង្ស៊ី ព្រះវិន័យធរអនុគណ ឯក- ញឹម . ១៥១

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២១០រ.១០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES


| PARTIE RELIGIEUSE: | | Page |
|---|---|---|
| — Editorial . . . . . . . . . | *Institut Bouddhique. . . . . .* | 83 |
| — Abhayadanapisès . . . . . . | *vén. SO-HAY . . . . . . .* | 87 |
| — Pannasajataka- vol 3 (suite) . | *M. CHHIM-SOUM . . . . . .* | 102 |

| PARTIE LITTERAIRE: | | |
|---|---|---|
| — Histoire de samkok (suite . . | *oknha NOU-KAN . . . . . .* | 118 |
| — Les trente deux récits du Trône (suite) | *M. RAY-BUC . . . . . . . .* | 122 |
| — Activité de la Commission des Mœurs et Coutumes Les Chansons) . . . . . . . . . . . | *M. CHAP-PIN. . . . . . . .* | 131 |

| NOTES ET CHRONIQUES: | | |
|---|---|---|
| — Réunion annuelle des digitaires religeux . . . . . . . . . | *Institut Bouddhique . . . . .* | 146 |
| — Transmission de mérites célébrée par le vén Brah Sasanamuni Meas-Kang . . . . . | *vén. EK-NHIM . . . . . . .* | 151 |


Prix d'abonnement annuel (comprenant 12 numéros) 210$00

# វិចារណកថា

## ធៀបពីរោះភ្លេងនឹងពីរោះធម៌

ភ្លេងជាគ្រឿងផ្ទើចិត្តនៃមនុស្សលោកឲ្យរំភើបរីករាយ, ភ្លេងនេះបើអ្នកចេះលេងជំនាញ រមែងជាទីពីរោះនៃអ្នកបានស្ដាប់ ។ តែភ្លេងរបស់ជនជាតិណា ជនជាតិនោះស្ដាប់ពីរោះ គឺថាខ្មែរស្ដាប់ភ្លេងខ្មែរពីរោះ ខ្មែរស្ដាប់ភ្លេងបារាំងមិនពីរោះ ។ ពាក្យនេះបានសេចក្ដីមកថា អ្នកស្ដាប់ភ្លេងពីរោះ មកពីស្ដាប់បាន មិនពីរោះមកពីស្ដាប់មិនបាន ។ ហេតុនេះសូម្បីខ្មែរស្ដាប់ភ្លេងខ្មែរ បើខ្លួនមិនចេះលេងភ្លេងនោះទេ ក៏ស្ដាប់ភ្លេងខ្មែរមិនពីរោះ ទោះបីខ្លួនជាជាតិខ្មែរ តែបើចេះលេងភ្លេងបារាំង ក៏អាចស្ដាប់ភ្លេងបារាំងពីរោះ ។ ដូច្នេះ ការពីរោះនឹងមិនពីរោះក្នុងរឿងស្ដាប់ភ្លេង មកតែពីអ្នកស្ដាប់ ចេះនឹងមិនចេះក្នុងល្បែងភ្លេងនោះឯង ។

សេចក្ដីនេះ សឲ្យឃើញច្បាស់ថា មនុស្សយើងបើបានអប់រំខ្លួនទុកក្នុងផ្លូវណា បានចេះចាំស្ទាត់ជំនាញហើយ ក្នុងពេលក្រោយមក កាលបើបានស្ដាប់ឮឬបានឃើញរបស់នោះ រមែងពីរោះឬពេញចិត្តចង់ស្ដាប់ចង់ធ្វើ ឧទាហរណ៍យ៉ាងអ្នកចេះច្រៀង ឮគេច្រៀង ក៏ចង់ច្រៀង, អ្នកចេះដាល់ ឃើញគេដាល់ ក៏ចង់ប្រដាល់, អ្នកចេះលេងចត្រង្គ, ឃើញគេលេងចត្រង្គ ក៏ចង់លេង, ចំណែកអ្នកមិនចេះវិញ សូម្បីស្ដាប់ឮហើយមើលឃើញហើយ ក៏គ្មានចិត្តស្រើបស្រាល ចង់ច្រៀង ចង់ដាល់ ចង់

លេងទេ ។ រឿងនេះ បំភ្លឺឲ្យយល់បានថា អ្នកដែលមានចិត្តបំណុលក្នុង ល្បែងទាំងនោះ មកពីគេពីរោះ បានជាគេពីរោះ មកពីគេបានអប់រំពីមុនៗ

ការស្តាប់ព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏មានទំនង យ៉ាងនេះដែរ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាក្នុងទី១ៗ មានពុទ្ធបរិស័ទ ស្តាប់រាប់ពាន់រាប់ម៉ឺននាក់ តែចំពោះអ្នកដែលស្តាប់ទៅហើយពីរោះ សម្រេចដល់គុណវិសេស មានសោតៈជាដើម មានតែម្នាក់ ឬពីរនាក់ ប៉ុណ្ណោះ ដូចកាលព្រះបរមគ្រូនៃយើងទ្រង់ស្តេចទៅសំដែងធម្មកថាអំពី មរណស្សតិ ក្នុងអគ្គាឡវវិហារ នាដែនអាឡវី ក្នុងទីប្រជុំនៃបរិស័ទច្រើន ពាន់ ។ ក្នុងពេលចប់ធម្មទេសនានោះ មានតែនាងពេសការធីតា (កូនស្រី ជាងតំបាញ) ម្នាក់ឯងទេ ដែលបានសម្រេចសោតាបត្តិផល ដោយហេតុ មុនស្តាប់ធម្មកថានេះ នាងបានភាវនាទាំងថ្ងៃទាំងយប់ នូវមរណស្សតិ អស់រវាង ៣ ឆ្នាំមកហើយ ។ រឿងនេះជួះឲ្យយល់ច្បាស់ថា អរិយសាវក ទាំងឡាយ ដែលបានសម្រេចមគ្គផលក្នុងពេលដែលស្តាប់ធម៌ព្រះសម្ពុទ្ធ ព្រោះអាស្រ័យកម្លាំងនៃអភិនិហារ កសាងទុកមកអំពីអតីតផង ។

វត្ថុនិទាន (រឿងរ៉ាវ) ដែលមានចែងក្នុងគម្ពីរធម្មបទដ្ឋកថា, ក្នុង រឿងមួយៗ លោកចែកពីរោះជា ៣ ជាន់ គឺ ១– ពីរោះបទដើម ដោយ ធ្វើឲ្យអ្នកស្តាប់ចង់ដឹងរឿងរ៉ាវ តើជាយ៉ាងណាទៅ ។ ២– ពីរោះបទ កណ្តាល ដោយការសំដែងធម៌ (គាថា) តភ្ជាប់ពីរឿងនោះមក ។ ៣– ពីរោះបទចុង ដោយការសំដែងញែកបំបែកធម៌នោះ (អដ្ឋកថា) ឲ្យល្អិតល្អន់ ធ្វើឲ្យអ្នកស្តាប់កាន់តែចូលចិត្តជ្រៅទៅៗ ។ តែរឿងនោះ

មានជនខ្លះបានស្តាប់ឬបានអានហើយ ត្រង់បទដើមក៏មិនពីរោះ បទកណ្តាលក៏មិនពីរោះ បទចុងក៏មិនពីរោះ; ជនខ្លះពីរោះតែបទដើម បទកណ្តាលនឹងបទចុង មិនពីរោះ, ជនខ្លះទៀត ពីរោះតែបទកណ្តាលនឹងបទចុង ត្រង់បទដើមមិនពីរោះ ។

ជនដែលមិនពីរោះទាំង ៣ ជាន់ គឺជនគ្មានបានអប់រំក្នុងផ្លូវវិជ្ជាមកសោះ ជាមនុស្សល្ងិតដូចយប់ ។ ជនដែលពីរោះតែបទដើម គឺជនដែលបានអប់រំ សិក្សាវិជ្ជាបានចេះដឹងយ៉ាងបង្គួរ ។ ជនដែលពីរោះតែបទកណ្តាលនឹងបទចុង គឺជនចេះដឹងជាន់ខ្ពស់ ត្រូវការចង់ស្តាប់តែសាច់ធម៌ មិនត្រូវការចង់ដឹងរឿងរ៉ាវ ។

ទស្សនាវដ្តីកម្ពុជសុរិយាយើង ក៏មានសេចក្តីពីរោះទំនងនឹងរឿងខាងលើនេះដែរ គឺពីរោះទី ១ ដោយអត្ថបទជាធម៌អាថ៌ផ្នែកសាសនា, ពីរោះទី ២ ដោយអត្ថបទផ្នែកអក្សរសាស្ត្រ, ពីរោះទី ៣ ដោយអត្ថបទជាកំណត់នឹងប្រត្តិការណ៍ ។ តែយើងក៏អាចដឹងទាន់ថា អ្នកអានទស្សនាវដ្តីយើង មិនមែនចេះតែពីរោះគ្រប់គ្នា គ្រប់ទាំង ៣ ជាន់ទេ អ្នកអានខ្លះពីរោះត្រង់អត្ថបទនេះ ខ្លះពីរោះត្រង់អត្ថបទនោះ, អ្នកអានខ្លះទៀត ក៏មិនពីរោះត្រង់ណាសោះ ។ ព្រោះហេតុនោះ ការធ្វើឲ្យពីរោះត្រូវគ្រប់ឋានៈនៃមនុស្ស ជាការណ៍ផុតវិស័យយើង មិនអាចធ្វើទៅបានទេ ស្រេចហើយតែអ្នកអានដែលបានអប់រំវិជ្ជាទុក ឬមិនបានអប់រំវិជ្ជាទុកពីមុន ដែលជាកាដ៌សម្រាប់ត្រងអត្ថរសនៃទស្សនាវដ្តីនេះ ដូចជាអ្នកស្តាប់ភ្លេងពីរោះនឹងមិនពីរោះដូច្នោះឯង ។

# ពីរោះតាមឋានៈនៃមនុស្ស

*កុមារសឹងពីរោះដោយសំដី      លួងលោមស្ដីថាឲ្យនំផ្អែមពីសា,*
*ប្រុសកំឡោះស្រីក្រមុំឆ្ងាញ់ពាក្យថា តែងកាយាដោយគ្រឿងនេះឆើតឆាវ ៗ*
*អ្នកជាប់គុកសឹងពីរោះពាក្យថារួច    ពីទោសលួចដែលពជការធ្វើពេញទី,*
*អ្នកមានរោគរុករានសព្វកាយឥន្ទ្រិយ    តែងសំភីពីរោះពាក្យប្រាប់ឱសថ ៗ*
*ពួកជនពាលសឹងពីរោះពាក្យទុច្ចរិត,    ពួកបណ្ឌិតពិតពីរោះពាក្យល្អផុត*
*ជាវាចាមានខ្លឹមសារយ៉ាងចំហុត,    សូមលំអុតបញ្ចប់រឿងពីរោះអើយ ៗ*

*ពុទ្ធសាសនបណ្ឌិត*

---

| សភាព ល្អ ៤ ពួក | |
|---|---|
| ១— ព្រះរាជាល្អ | ព្រោះទ្រង់ទសពិធរាជធម៌, |
| ២— នរជនល្អ | ព្រោះមានប្រាជ្ញា, |
| ៣— មិត្តភក្តិល្អ | ព្រោះមិនប្រទុស្តមិត្ត, |
| ៤— សេចក្ដីសុខមាន | ព្រោះមិនធ្វើបាប ៗ |

# ផ្នែកសាសនា

## អភយទានពិសេស

ព្រះឧបាលិវង្ស ស៊ូរ-ក្រាយ វត្តឧណ្ណាលោម

ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការចំពោះព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ (ព្រមទាំងព្រះធម៌នឹងព្រះសង្ឃ ដោយសេចក្ដីគោរព) ។

លំដាប់នេះ សូមសំដែងអំពី អភយទានពិសេស ដូចដំណើរសេចក្ដីដែលនឹងអធិប្បាយ បរិយាយតាមហេតុផល ទុកជាសណ្ដាប់នៃពុទ្ធបរិស័ទតទៅ ។

ពាក្យថា អភយទាន នេះ បានសេចក្ដីថា ការឲ្យឱកាសដល់មនុស្សសត្វ មិនឲ្យមានភ័យ គឺថាទុកដាក់ខ្លួនយើងមិនឲ្យជាសត្រូវដល់មនុស្សនឹងតិរច្ឆាន ដោយការធ្វើខ្លួនយើងមិនឲ្យមនុស្សនឹងពួកសត្វមានសេចក្ដីភិតភ័យព្រោះហេតុតែយើង ។

ពាក្យថា ពិសេស បានសេចក្ដីថា ដោយឡែក, គុណដែលគួរសរសើរ, ដែលប្លែកលើសលន់ ។ រួមសេចក្ដី: ពាក្យដែលហៅថា "អភយទានពិសេស" នេះ សំដៅយកការឲ្យអភ័យចំពោះពួកសត្វ ៣

ប្រភេទ ដែលជាបសុសត្វមានឧបការៈច្រើនមានគោជាដើម ដូចសេចក្តីពណ៌នាតទៅនេះ ៖

បសុសត្វ (សត្វចិញ្ចឹម) មានច្រើនប្រភេទគឺ គោ, ក្របី, សេះជាដើម ។ គោ ក្របី សេះ ជាពាហនៈរបស់មនុស្សគ្រប់ប្រទេស ។ មនុស្សទាំងអស់ សុទ្ធតែបានអាហារអំពីកម្លាំងគោក្របី ដែលជាសត្វបម្រើរបស់អ្នកធ្វើស្រែចំការ ។ កម្លាំងរបស់គោក្របីបណ្តាលឱ្យកើតបានស្រូវ អង្ករ ល្ង សណ្តែក ពោតជាដើម សម្រាប់ចិញ្ចឹមមនុស្សក្នុងលោក ។ ផលិតផល ដែលកើតអំពីធរណីទាំងប៉ុន្មាន ក៏សុទ្ធតែកើតមកអំពីកម្លាំងគោក្របី ។ អ្នកធ្វើស្រែចំការត្រូវមានគោក្របីនេះឯងជាដើមទ្រព្យ, គោក្របីនេះ ជាដើមសេដ្ឋកិច្ចរបស់មនុស្សគ្រប់ប្រទេស, ជាបសុសត្វមានឧបការគុណយ៉ាងធំលើមនុស្ស គួរណាស់តែបសុសត្វពួកនេះបានទទួលអភយទានអំពីមនុស្ស ។

គោក្របីជាសត្វបម្រើ ក្នុងការទ័មរទេះបរដឹកនាំអីវ៉ាន់គ្រប់មុខ, ក្នុងការភ្ជួររាស់ដីស្រែចំការ, ក្នុងការជះបម្លងកាត់ទឹកភក់ ដែលយើងមិនអាចដើរទៅដោយជើងបាន ។ គោក្របីជាសត្វមានប្រយោជន៍ធំបំផុតដែលអាចជួយជីវិតមនុស្សយើងឱ្យរស់នៅសព្វថ្ងៃនេះ គួរតែគោក្របីបានទទួលអភយទានអំពីមនុស្សដោយពិត ។ ប៉ុន្តែបណ្តាមនុស្សទាំងអស់មិនសូវដែលឮអ្នកណាមួយនិយាយសរសើរថា "គោក្របីនេះមានឧបការ-គុណណាស់ ។ ជនជាតិខ្មែរអ្នកមានធម៌សប្បុរសនៅខេត្តត្រាំ ក្នុងកាលពីដើមមិនសូវមានអ្នកបេះបរិភោគសាច់គោក្របីទេ, អ្នកខ្លះដែលមាន

គោក្របីស្លាប់ និមន្តព្រះសង្ឃបង្សុកូល ឧទ្ទិសកុសលបញ្ជូនទៅឲ្យគោក្របីដែលស្លាប់នោះ រួចហើយក៏យកទៅកប់ ។ អ្នកខ្លះដល់ថ្ងៃបុណ្យភ្ជុំបិណ្ឌ ឈប់ភ្ជួររាស់អស់ ២ ថ្ងៃក៏មាន ៣ ថ្ងៃក៏មាន, គេលាងទឹកគោក្របីឲ្យជ្រះស្អាតល្អ ហើយយកប្រេងម្សៅលាបក្បាលនឹងស្នែង រួចខមាទោសចំពោះមុខគោក្របីនោះ ដោយពាក្យជំទន់ភ្លន់ថា "យើងបានយកឯងមកជាពាហនៈទឹមប្រើ ភ្ជួររាស់ដឹកនាំ ឥឡូវនេះដល់ថ្ងៃខែបុណ្យភ្ជុំបិណ្ឌ, យើងលាងទឹកលាបប្រេងម្សៅឲ្យឯងរាល់គ្នា ដែលយើងបានប្រើប្រាស់ជេរស្តីវាយប្រដៅបន្តិចបន្តួច, សុំឲ្យឯងរាល់គ្នា កុំចងកម្មពៀរនឹងយើង ទាំងយើងក៏សុំកុំឲ្យមានកម្មពៀរនឹងឯងរាល់គ្នាហ្ន៎ ។" ។

មនុស្សជាន់ពីដើម បើតាមសង្កេតទៅឃើញថា មានឧត្តមគតិបរិសុទ្ធណាស់ មិនសូវមានអ្នកឃាតគោក្របីទេ ទាំងអ្នកដែលចេះបរិភោគសាច់គោក្របីក្នុងឃុំនីមួយ ៗ ក៏មិនសូវមានឡើយ ។ មនុស្សជាន់មុន ប្រើគោក្របីប្រកបដោយចិត្តមេត្តាករុណា ដោយបានឃើញគេបំប៉នស្មៅនឹងទឹកឲ្យឆ្អែតស្កប់ស្កល់ល្អណាស់ ។ អ្នកខ្លះច្រូតស្រូវសំទូងដែលល្អឲ្យគោក្របីបរិភោគឲ្យបានឆ្ងាញ់ម្តងមួយកាល ។

សេះជាពាហនៈសម្រាប់បម្រើមនុស្សដែលត្រូវការជិះក៏បាន ទឹមរទេះក៏បាន ។ សេះជាសត្វមានកម្លាំងអត់ធ្មត់មានល្បឿនលឿនជាងសត្វទាំងអស់ មិនឆាប់ហត់នឿយសន្ទាបញើសដូចគោក្របីទេ ។ សេះរាប់ថាជាសត្វមានប្រយោជន៍ក្នុងការជិះដោយមានការប្រញាប់ ។ សង្គ្រាមជើងគោកតាំងពីសម័យព្រេងនាយរហូតដល់បច្ចុប្បន្ននេះ, គេតែងប្រើសេះជា

ពាហនៈកង់សង្គ្រាម បាលីហៅថា "អស្សានិក" ប្រែថា "កងទ័ពសេះ" ឬថា "ពួកទាហានសេះ", សេះក៏រាប់ថាជាបសុសត្វមានឧបការៈដល់មនុស្សបន្ទាប់បន្សំនឹងគោក្របីដែរ ។ អ្នកប្រើសេះក៏គួរតែថ្នាក់ថ្នមដោយមេត្តាករុណា ហើយគួរតែឲ្យអភ័យដល់ជីវិតបសុសត្វនេះកុំខាន ។

## ប្រជាជនឥណ្ឌាមិនបរិភោគសាច់គោក្របី

ប្រជាជនភាគច្រើននៅប្រទេសឥណ្ឌាដែលកាន់សាសនាព្រាហ្មណ៍នឹងសាសនាព្រះពុទ្ធ វៀរលែងតែពួកអ្នកកាន់សាសនាឥស្លាម មិនបរិភោគសាច់គោក្របីទេ គេទុកជាសត្វមានឧបការគុណជាទីបំផុត, សូម្បីកាលនៅក្រោមអំណាចរដ្ឋាភិបាលអង់គ្លេស អ្នកដែលធ្វើការរេជការជាមួយនឹងអង់គ្លេស ទោះបីអង់គ្លេសនិយាយដឹកនាំយ៉ាងណា ក៏មិនព្រមបរិភោគសាច់គោដោយដាច់ខាត ។ ឥឡូវនេះ រដ្ឋាភិបាលបណ្ឌិតនេហ្រុ ប្រទេសឥណ្ឌា បានបញ្ញត្តទូទៅក្នុងអាណាចក្រទាំងមូល តាមផ្លូវការហាមឃាត់មិនឲ្យពិឃាតគោក្របី ។ បើអ្នកណាលបពិឃាតនឹងត្រូវទោសជាទម្ងន់ ប្រហែលគ្នានឹងទោសពិឃាតមនុស្សដែរ ។ អ្នកប្រទេសឥណ្ឌាភាគច្រើនមិនបរិភោគសាច់សត្វ សូម្បីសាច់មាន់ទាជ្រូកក៏គេមិនបរិភោគ ដើម្បីរក្សារាងកាយឲ្យប្រកបដោយអនាម័យ ឲ្យរាងកាយមានសុខភាពល្អ ដោយគេយល់ឃើញថា សាច់ជាហេតុនាំឲ្យកើតរោគច្រើនយ៉ាង មានលោហិតរោគជាដើម ។ លោហិតរោគ (រោគឈាមលើស) ដែលនាំឲ្យខ្លួនយើងមានរោគដាច់សរសៃ ក៏ព្រោះទោសលោភបរិភោគសាច់

បណ្ដាលហេតុឲ្យមនុស្សមានស្លាប់ជាច្រើន ។ គេតមសាច់គោក្របីតឹងរឹងបំផុតដូចពួកចាមផ្ទាតមសាច់ជ្រូកដែរ ។ មួយទៀត ជនជាតិឥណ្ឌាដែលកាន់សាសនាព្រាហ្មណ៍ ឬកាន់សាសនាព្រះពុទ្ធសព្វថ្ងៃនេះ ដែលតមត្រីសាច់ កាន់តែច្រើនណាស់ហើយ ដោយគេយល់ឃើញហេតុ ៥ យ៉ាង គឺ

១– ការមិនបរិភោគត្រីសាច់នេះ ឈ្មោះថាជាជីវិតទានដល់ពួកសត្វតិរច្ឆានគ្រប់ប្រភេទ ។

២– អហឹសាលទ្ធិ (លទ្ធិមិនបៀតបៀនមនុស្សសត្វ) ជាលទ្ធិរបស់រដ្ឋបុរសមួយរូបឈ្មោះ មហាត្មគន្ធី ដែលជាលទ្ធិល្អគួរគោរព គួរជឿ ។

៣– សាសនាព្រាហ្មណ៍ មានបវត្តិការណ៍តាំងអំពីព្រេងនាយយូរលង់ណាស់ហើយថា បើអ្នកណាបរិភោគសាច់គោក្របី, គេកាត់កាល់លែងរាប់អានអ្នកនោះថាជាអារ្យមនុស្សហើយ, គេទុកជាក់អ្នកបរិភោគសាច់គោក្របីថាជាអនារ្យមនុស្ស បានដល់មនុស្សចណ្ឌាលឬមនុស្សមិលក្ខជាតិ គឺជាតិមនុស្សថោកទាប, មនុស្សមានជាតិអាក្រក់, មនុស្សព្រៃផ្សៃ ។

៤– គោក្របីជាសត្វមានឧបការៈដល់មនុស្សដែលអាចជួយជីវិតមនុស្សដោយកម្លាំងកាយច្រើនណាស់ ទាំងជាសត្វស្លូតបូត ។

៥– គោជាបសុសត្វដែលមនុស្សគួរដឹងគុណបំណាច់ ព្រោះថាក្នុងសាសនាព្រាហ្មណ៍មានដំណាលរឿងថា “គោជាឈ្មោះទេវបុត្រមួយអង្គ ជាពាហនៈ គឺជាយានជំនិះរបស់ព្រះសិវៈ (ព្រះឥសូរ) ដែលបិតនៅ

គង់បានសួគ៌ទេវលោក" ។ គោទេវបុត្រនេះឈ្មោះ នន្ទិ ដែលគេហៅថា "គោនន្ទិទេវបុត្រ" ។ ទេវបុត្រនោះតែងតំណែងខ្លួនធ្វើជាគោ ដើម្បីជាយានជំនិះថ្វាយព្រះសិវៈ ដែលត្រូវការជិះទៅកាន់ទីណាមួយ ។ គោនន្ទិទេវបុត្រនេះ ជាអ្នកបំរើយ៉ាងសំណាប់របស់ព្រះសិវៈដែលឥណ្ឌៀឲ្យនាមថា "គោឧសភរាជ" គឺស្តេចគោឈ្មោល ។ ខ្មែរយើងធ្លាប់កាន់សាសនាព្រាហ្មណ៍ដែរ បានជាមានពាក្យថា "ព្រះគោ" ដោយការជាប់ចិត្តគោរពគោនោះទេដឹង? មានទាំងពាក្យហៅថា "ព្រះគោព្រះកែវ" ។ ពាក្យថា "ព្រះគោព្រះកែវ" នេះ ប្រហែលជារូបគោដែលគេកសាងទុកជាតំណាងនៃគោនន្ទិទេវបុត្រ, ទាំងរូបគោនោះគេធ្វើអំពីកែវ ឬក៏សំដៅព្រះពុទ្ធរូបកែវមរកតទេដឹង?

អាស្រ័យហេតុ ៥ យ៉ាងនេះហើយ បានជាពួកអ្នកកាន់សាសនាព្រាហ្មណ៍ប្រទេសឥណ្ឌាគោរពគោ មិនបរិភោគសាច់គោដរាបមក ។

ហេតុ ៥ យ៉ាងដូចពោលមកខាងលើនេះ អាចបញ្ញត្តរាំងជនជាតិអ្នកកាន់សាសនាព្រាហ្មណ៍មិនឲ្យបរិភោគត្រីសាច់ ។ ប្រជាជនជាតិខ្មែរយើងក៏គួរពិចារណាតាមហេតុ ៥ យ៉ាងនេះដែរ ប៉ុន្តែត្រង់ហេតុទី ៥ នោះ មានគម្ពីរជាតកក្នុងពុទ្ធសាសនារបស់យើងថា "ព្រះសម្មាសម្ពុទ្ធកាលនៅជាពោធិសត្វ ដែលកំពុងត្រាច់រង្គាត់ក្នុងកពវដ្តសង្សារនៅឡើយ ព្រះអង្គក៏ធ្លាប់យកជាតិជាគោដែរ" ។

គម្ពីរជាតកក្នុងពុទ្ធសាសនា មានអតីតនិទានដំណាលថា កាលព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់យើង កំពុងអន្ទោលយោនយកកំណើតនៅក្នុង

បាន:ជាព្រះពោធិសត្វ ដែលនៅត្រាច់ត្រាត់ក្នុងកលវដ្ដសង្សារនៅឡើយ. ព្រះអង្គធ្លាប់ចាប់ជាតិកំណើតជាគោ ដែលមានក្នុងជាតកហៅថា "កណ្ហ-ឧសភជាតក" និង "នន្ទិវិសាលជាតក" ។ ជាតកនៃព្រះពោធិសត្វ ដែលធ្លាប់ចាប់ជាតិជាគោពីរជាតិនេះ សឹងមានប្រាកដនៅក្នុងគម្ពីរជាតក ឯណោះស្រាប់ហើយ ។ យើងអ្នកកាន់ព្រះពុទ្ធសាសនា កាលបើពិចារណាដល់រឿងជាតករបស់ព្រះពោធិសត្វ ដែលទ្រង់ធ្លាប់យកជាតិជាគោនេះ. យើងគួរមានចិត្តមេត្តាករុណាដល់គោ. មិនគួរនឹងហ៊ានពិឃាតគោ ឬបរិភោគសាច់គោសោះឡើយ ។ កាលព្រះអង្គបានត្រាស់ដឹងគង់ក្រោមម្លប់ពោធិព្រឹក្ស, យើងជាពុទ្ធបរិស័ទ តែងមានសេចក្ដីគោរពចំពោះពោធិព្រឹក្ស មិនហ៊ានកាប់ដើមពោធិព្រឹក្សទេ សូម្បីពាក់មួកប្ប៉ាំងឆ័ត្រដើរក្រោមដើមពោធិព្រឹក្ស ក៏យើងមិនហ៊ាន ។ បំណែកខាងពោធិព្រឹក្សដែលយើងគោរពយ៉ាងណា. គោក៏យើងគួរគោរពយ៉ាងនោះដែរ ។ ករណីនេះកាលបើយើងពិចារណាដោយហ្មត់ចត់ មិនគួរហ៊ានបរិភោគសាច់គោឡើយ ។

ពួកតិរច្ឆានក្រៅពីគោ ដូចយ៉ាងដំរី, ត្រីរស់, ចាបជាដើមក៏មានជាតកដែលនិយាយអំពីព្រះសម្មាសម្ពុទ្ធធ្លាប់ចាប់ជាតិដែរ ប៉ុន្តែជារឿងជាតកកន្លងទៅជាយូរអង្វែងណាស់ហើយ, មួយទៀតដូចយ៉ាងដំរី ជាសត្វចតុប្បាទមានខ្លួនធំណាស់ ប៉ុន្តែជាសត្វមិនសូវមានប្រយោជន៍ច្រើនដូចគោក្របីទេ បំណែកខាងត្រីរស់និងចាបជាដើម ជាតិរច្ឆានតូចតាចមិនរាប់ជាជាបសុសត្វ (សត្វចិញ្ចឹម) ទេ តែបើពុទ្ធបរិស័ទមានសេចក្ដី

គោរពដោយការមិនបៀតបៀន មិនបរិភោគសត្វទាំងនេះបាន ក៏រឹតតែប្រសើរណាស់ទៅទៀត ។

## គោព្រះរាជទ្រព្យក្នុងពិធីច្រត់ព្រះនង្គ័ល

នៅប្រទេសកម្ពុជាយើងមានទំនៀមព្រះរាជពិធីច្រត់ព្រះនង្គ័ល ។ ពិធីនេះជារបស់ព្រះមហាក្សត្រ ដែលតែងធ្វើមករៀងរាល់ឆ្នាំមិនដែលដាច់, ព្រះរាជពិធីនេះយកគោមកទឹមនង្គ័លរួចថ្វាយព្រះមហាក្សត្រដើម្បីច្រត់ភ្ជួរជាកិច្ចមង្គលនាំមុខបណ្ដាកសិករ ដើម្បីពិសោធន៍សម្បូរសម្បែងឲ្យប្រជាជនធ្វើស្រែក្នុងឆ្នាំនេះបានផលបរិបូណ៌ បានសុខសប្បាយក្នុងការធ្វើស្រែ ។ គោមួយទឹមដែលយកមកទឹមក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លនោះ ជាគោព្រះរាជទ្រព្យហៅថា គោឧសភរាជ ដែលចិញ្ចឹមទុកជាទីស្រឡាញ់ប្រោសប្រាណដោយមេត្តាករុណាដ៏ល្អបំផុត ។ គោមួយទឹមរបស់ព្រះរាជទ្រព្យនោះ ជាសត្វមានភ័ព្វសំណាងល្អណាស់ ដែលរួចខ្លួនអំពីការពិឃាត ដោយការទទួលអភ័យទានអំពីព្រះមហាក្សត្រិយ៍, ឯគោក្រៅពីនេះមិនទាន់ដែលបានទទួលអភ័យទានសោះ ។

## ប្រទេសភូមាបញ្ញត្តមិនឲ្យពិឃាតគោក្របី

ប្រទេសភូមាដែលទើបរួចអំពីអាណានិគមអង់គ្លេសថ្មីៗ បានទទួលឯករាជ្យបរិបូណ៌, ឥឡូវនេះព្រឹទ្ធសភារដ្ឋាភិបាលភូមា បានបញ្ញត្តដាច់ខាតមិនឲ្យពិឃាតគោក្របីដូចប្រទេសឥណ្ឌាដែរ លុបបំបាត់មិនឲ្យមានសមាគម (ក្រុមហ៊ុន) ពិឃាតគោក្របីឡើយ ទុកឲ្យនៅមានតែសមាគមពិឃាតជ្រូក

ពពៃមាន់ទាប៉ុណ្ណោះ ដោយគេយល់ឃើញថា គោក្របីនេះជាសត្វមានគុណូបការៈ ជាប្រយោជន៍ជួយបំពេញករណីយកិច្ចរបស់មនុស្សយ៉ាងធំណាស់ ត្រូវតែឲ្យអភ័យដល់សត្វពួកនេះ មិនត្រូវពិឃាតឡើយ, គោក្របីនេះ យើងត្រូវចិញ្ចឹមគ្រាន់តែទុកចំមប្រើ ឬត្រូវយកទឹកដោះប៉ុណ្ណោះ មិនត្រូវពិឃាតយកសាច់មកធ្វើជាអាហារឡើយ គេបានតាំងបង្កើតសមាគម សម្រាប់ទទួលយកគោក្របីចាស់ៗ ចិញ្ចឹមទុកឲ្យទាល់តែស្លាប់ថែមទៀត ព្រោះហេតុនោះត្រូវតែយើងមានមេត្តាករុណាទំនុកបំរុងតាមសមគួរដល់សត្វដែលមានឧបការៈដូចយ៉ាងគោក្របីនេះ ។

ប្រទេសកម្ពុជាយើង ជាប្រទេសកាន់ព្រះពុទ្ធសាសនាដូចប្រទេសឥណ្ឌា ក្តីមាដែរ តាំងឯកកជ្យក៏មានកេតនកណ្ឌកាន់តែក្តីថ្វាបរិបូណ៌ហើយ គួរតែចែកសិទ្ធិឯកកជ្យដល់គោក្របីឲ្យគ្នារួចអំពីការពិឃាតផង ។ យើងអ្នកកាន់ព្រះពុទ្ធសាសនា ស្គាល់សិក្ខាបទទី ១ របស់និច្ចសីល ជាពុទ្ធបញ្ញត្តិដែលព្រះអង្គហាមមិនឲ្យសម្លាប់សត្វនោះស្រាប់ហើយ សូម្បីសត្វល្អិតៗ មានសង្កើចចៃជាដើមក៏ត្រូវហាមទាំងអស់ ។ ចំណែកខាងសត្វមាន់ទាជ្រូកជាបសុសត្វដែរ ប៉ុន្តែគេមិនរាប់ថាជាពាហនៈទេ ឯគោក្របី ជាសត្វបម្រើមានឧបការៈជួយកម្លាំងមនុស្សបានធំធូលាយណាស់, គួរតែយើងអ្នកកាន់ព្រះពុទ្ធសាសនាឲ្យអភ័យ, ឲ្យសិទ្ធិដល់គោក្របីឲ្យគ្នារួចខ្លួនស្រឡះអំពីការពិឃាត ទើបឈ្មោះថាយើងអ្នកមានមនុស្សធម៌ ឬយុត្តិធម៌ដ៏ប្រសើរ របស់មនុស្សអ្នកមានធម៌វិន័យក្នុងព្រះពុទ្ធសាសនាដោយពិតផង ឈ្មោះថាយើងបានរក្សាវិរតិសីលពិសេសផង ។

គោក្របីជាសត្វមានកម្លាំងឲ្យប្រើប្រាស់ ជាប្រយោជន៍ដល់មនុស្ស, គួរយើងជាមនុស្សប្រើប្រាស់ដោយសេចក្ដីករុណាអាណិតអាសូរ, យើងជាមនុស្សត្រូវតែមិនសមបើធ្វើចិត្តទុច្ចរិតអាក្រក់ឥតមេត្តាករុណា, ឥតនឹកឃើញឧបការៈរបស់គោក្របី ដែលយកគ្នាមកប្រើជួយកម្លាំងដើម្បីបានប្រយោជន៍ បានសុខមកខ្លួនជាច្រើនណាស់, បើតាមសង្កេតដោយយុត្តិធម៌ដ៏បរិសុទ្ធ ឃើញថាមិនគួរហ៊ានប្រមាថពាធធន្ទ, ហ៊ានពិឃាត, ហ៊ានបរិភោគសាច់គោក្របីសោះឡើយ ។ ការពិឃាតគោក្របីនេះជាអកតញ្ញូតា ជាអំពើបាបឬជាអំពើទុច្ចរិតអយុត្តិធម៌មួយដែលគួរឲ្យស្អប់ស្អែងយ៉ាងធំក្រៃលែងរបស់មនុស្សអ្នកកាន់ធម៌ ក្នុងពុទ្ធសាសនា ។ សូម្បីក្នុងគម្ពីរក៏មានសំដែងថា សម្លាប់សត្វមានគុណធំ មានទោសធំដែរ ។

យើងអ្នកកាន់ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា កាលបើពុំដំណឹងថា ប្រទេសឥណ្ឌានឹងប្រទេសភូមាឲ្យអភ័យដល់គោក្របី ដោយការវៀរស្រឡះអំពីការពិឃាតគោក្របីដូច្នោះហើយ ប្រហែលជាលោកអ្នកសប្បុរសខ្លះ ដែលធ្លាប់មានព្រហ្មវិហារធម៌នឹកក្នុងចិត្តដោយសោមនស្សត្រេកអរអនុមោទនាចំពោះប្រទេសនោះពុំខាន ព្រោះគោលបំណងរបស់យើងអ្នកកាន់ព្រះពុទ្ធសាសនា ដែលយើងធ្លាប់វៀរចាកបាណាតិបាតមកក៏មានស្រាប់ហើយ ។ ត្រីសាច់ទាំងអស់គេធ្លាប់រាប់អានថាជាអាហារក៏ពិតមែនហើយ ប៉ុន្តែយើងអ្នកកាន់ព្រះពុទ្ធសាសនា គួរពិចារណាអាហារផង ដូចយ៉ាងសាច់គោក្របី មិនគួរយកមកធ្វើជាអាហារសម្រាប់

មនុស្សអ្នកមានសីលធម៌សោះ, អ្នកលោកស៊ីសាច់ ច្រើនតែស្រូតទៅរកសុកមកដឹកក្រៀមថែមទៀតក៏មាន នាំបណ្ដាលឲ្យស្រវឹងខូចប្រាជ្ញាស្មារតី នាំបង្កជម្លោះទាស់ទែងក៏យកកាប់គ្នាក៏មាន ។

គោក្របីដែលយើងពុំគួរសំឡាប់នោះដោយហេតុ ៦ យ៉ាង :

១- ព្រោះហេតុថា បសុសត្វមានឧបការៈគុណច្រើនដល់មនុស្ស

២- ព្រោះហេតុថា អ្នកសំឡាប់សត្វដែលមានកាយធំ ត្រូវមានទោស ជាមហាសាវជ្ជៈ (ទោសច្រើន)

៣- ព្រោះហេតុថា គោជាតិរច្ឆានដែលព្រះបរមពោធិសត្វធ្លាប់ចាប់ជាតិដែរ

៤- ព្រោះហេតុថា សាច់គោក្របីកាលបើអ្នកលោកបរិភោគអាចបណ្ដាលឲ្យកើតរោគច្រើនយ៉ាងមានលោហិតរោគ (រោគឈាមលើស) ជាដើម ដែលជាហេតុនាំឲ្យដាច់សរសៃស្លាប់ដោយឆាប់

៥ ព្រោះហេតុថា យើងជាមនុស្សត្រឡាំងពុំគួរទុកដាក់ខ្លួនជាមនុស្សអកតញ្ញូចំពោះគោក្របីសោះ

៦- ព្រោះហេតុថា ប្រទេសឥណ្ឌា-ភូមាដែលជាពុទ្ធសាសនិកដូចយើងដែរ គេតមដាច់ខាតក្នុងការពិឃាតគោក្របី ។

គោក្របីនេះ ជាសត្វជួយស្រោចស្រង់ជីវិតមនុស្ស ឲ្យរស់នៅឲ្យប្រយោជន៍ធំណាស់ ។ យើងជាមនុស្សនៅក្នុងសង្គមមនុស្ស ទាំងគោក្របីដែលជាបសុសត្វ ក៏យើងយកមកប្រើប្រាស់ជួយជាកម្លាំង នៅក្នុង

សង្គមជាមួយនឹងយើងជាមនុស្សដែរ ។ យើងគួរចិញ្ចឹមទុកដើម្បីគ្រាន់តែប្រើប្រាស់ដោយការទឹមរទេះដឹកនាំ, ទឹមនង្គ័លភ្ជួររាស់ដោយចិត្តដ៏ត្រជាក់ប្រកបដោយមេត្តាករុណាប៉ុណ្ណោះបានហើយ, មិនគួរយើងសម្លាប់ជីវិតយកសាច់បរិភោគ ឬលក់ទៅឲ្យឈ្មួញដែលទិញយកទៅឲ្យសមាគមពិឃាតសោះឡើយ, គួរឲ្យអាណិតអាណោចខ្លោចផ្សាចំពោះគោក្របីពន់ពេកណាស់ ។ បើយើងមិនបានធ្វើកិច្ចតបគុណណាមួយដល់គោក្របីក៏ហើយទៅចុះ, យើងកុំតែពិឃាតឬកុំលក់ៈទៅឲ្យអ្នកពិឃាតក៏ឈ្មោះថាយើងមានសប្បុរិសធម៌ក្នុងសន្តាន សមគួរដល់មនុស្សធម៌ណាស់ហើយ ។

ប្រជាជនប្រទេសឥណ្ឌា ទាំងអ្នកកាន់សាសនាព្រះពុទ្ធ ទាំងអ្នកកាន់សាសនាព្រាហ្មណ៍ តែងពោលពាក្យរិះគន់ពេបជ្រាយចំពោះអ្នកដែលបរិភោគសាច់គោក្របី ថាជាមិលក្ខជាតិ គឺជាតិនៃមនុស្សអាក្រក់ថោកទាបជាទីបំផុត ។ មួយទៀត ជនដែលគេហៅថាមិលក្ខជាតិនោះ ដោយគេសំគាល់មនុស្ស ៣ ពួក ៖

១— គោមំសភក្ខកោ ជនអ្នកស៊ីសាច់គោ

២— លោកវិក្ខញ្ញ ភាសតេ អ្នកនិយាយពាក្យ តែខាងផ្លូវលោក

៣— សព្វាចារវិហីនោ ជាអ្នកប្រាសចាកមារយាទគ្រប់យ៉ាង ។

ប្រជាជនឥណ្ឌាយល់ថា គោទុកជាម្ដាយរបស់មនុស្ស ព្រោះថាទារក ទារិកាដែលកើតអំពីម្ដាយ ជួនកាលម្ដាយមានជម្ងឺកាត់ណាមួយ

មិនមានទឹកដោះបំបៅកូនក៏មាន ម្ដាយស្លាប់ចោលកូនទៅក៏មាន ។ ទារក ទារិកា ទាំងនោះ ក៏ត្រូវគេចិញ្ចឹមឲ្យរស់នៅបាន ដោយទឹកដោះគោ, ព្រោះហេតុនោះ កាលបើអ្នកណាមួយហ៊ានពិឃាតគោឬស៊ីសាច់គោ, អ្នកនោះទុកដូចជាអ្នកពិឃាតម្ដាយ ឬស៊ីសាច់ម្ដាយរបស់ខ្លួន ។

ពាក្យឬរឿងរ៉ាវដែលត្រូវនិយាយ មានច្រើនយ៉ាងពិតមែន ប៉ុន្តែ បើបំប្រួញដោយខ្លីមានតែ ២ យ៉ាងគឺ លោកវាក្យៈ ពាក្យដែលនិយាយក្នុងរឿងផ្លូវលោក ១, ធម្មវាក្យៈ ពាក្យដែលនិយាយក្នុងរឿងផ្លូវធម៌ ឬប្រកបដោយធម៌ ១ ។ ពួកជនណាច្រើនចូលចិត្តនិយាយតែខាងផ្លូវលោកម្យ៉ាង មិននិយាយផ្លូវធម៌ផង, ពួកជននោះគេតែងរិះគន់ថាជាមនុស្សថោកទាប ។

ពាក្យថា "ប្រាសចាកមារយាទគ្រប់យ៉ាង" បានដល់បុគ្គលអ្នកប្រព្រឹត្តក្នុងផ្លូវអបាយមុខ មានការលេងល្បែងស៊ីសង ទ័ងការផឹកសុរាជាដើម ។ ពួកជនណា ជាអ្នកប្រកបដោយមារយាទថោកទាប មានការប្រព្រឹត្តក្នុងផ្លូវអបាយមុខជាដើម ពួកជននោះគេតែងហៅថា អនារ្យមនុស្ស គឺមនុស្សពុំប្រសើរឡើយ ។ សមដូចបាលីលោកនីតិរបស់ប្រទេសឥណ្ឌាថា ៖

គោមំសភក្ខកោ យោ តុ លោកវាក្យញ្ច ភាសតេ
សញ្ញាចារវិហីនោយំ មិលក្ខជាតិ វុច្ចតេ ។
យេ ប ខាទន្តិ គោមំសំ មាតុមំសំវ ខាទយេ
មតេសុ តេសុ គិជ្ឈានំ ទទេ សោតេ ប វាហយេ ។

ប្រែថា " ជនណាជាអ្នកស៊ីសាច់គោ ១ និយាយតែរឿងផ្លូវលោក ១ ជាអ្នកប្រាសចាកមារយាទគ្រប់យ៉ាង ១ ជននោះគេតែងហៅថា មិលក្ខជាតិ ។

ពួកជនណាស៊ីសាច់គោ ពួកជននោះ ទុកដូចជាស៊ីសាច់ម្ដាយរបស់ខ្លួន កាលបើគោក្របីស្លាប់ យើងគួរឲ្យទានដល់ត្មាតទាំងឡាយ ឬយកទៅបន្សាត់ចោលក្នុងខ្សែទឹក" ។

សេចក្ដីនេះ ជាបវេណីធម៌របស់ប្រជាជនឥណ្ឌៀដែលជាអ្នកកាន់សាសនាដ៏ឧក្រិដ្ឋ ។

ដំណើរសេចក្ដីអធិប្បាយអត្ថបទ អំពីការឲ្យអភ័យដល់គោក្របី ដូចហេតុផលដែលអាងមកនេះ ដើម្បីឲ្យពុទ្ធបរិស័ទក្នុងប្រទេសកម្ពុជាយើងពិចារណាតទៅ ។ បទបញ្ញត្តិអំពីការពិឃាតគោក្របីនេះ ជាភារៈនៅលើយើងទាំងឡាយជាអ្នកកាន់ព្រះពុទ្ធសាសនា, បើយើងពិចារណាឃើញជាក់ច្បាស់ហើយ ព្រមព្រៀងគ្នាមិនបរិភោគសាច់គោក្របី អ្នកសម្លាប់គោក្របីក៏មិនសូវមាន. យើងទាំងឡាយក៏ឈ្មោះថា ឲ្យអភ័យដល់ជីវិតគោក្របី ។ បើទុកជានៅមានអ្នកសម្លាប់ក៏មានចំនួនតិចដែរ ប៉ុន្តែដំណើរការពិឃាតគោក្របីនេះ បើជាករដ្ឋាភិបាល ពិចារណាឃើញថា ការបិទសមាគមពិឃាតគោមិនខាតផលសេដ្ឋកិច្ចប៉ុន្មានទេ អាចចេញច្បាប់បញ្ញត្តជាផ្លូវការទូទៅ ក្នុងព្រះរាជអាណាចក្រទាំងមូល, ហាមផ្ដាច់មិនឲ្យពិឃាតគោក្របី ដូចប្រទេសឥណ្ឌា-ភូមាបាននោះ

ជាការប្រសើរណាស់ ។ ឯសមាគម (កុងស៊ី) ពិឃាតគោដែលធ្លាប់មានពីមុនមក ក៏ត្រូវបំបាត់ចោលឲ្យអស់កុំឲ្យពិឃាតគោជាដាច់ខាត ។ បើជារាជរដ្ឋាភិបាលអាចបញ្ញត្តដូច្នេះបាន ប្រហែលជាប្រជាជនអ្នកកាន់ពុទ្ធសាសនា ដោយភាគច្រើន មានសេចក្តីត្រេកអរសាទរជាអនេកបរិយាយ ។ ឯការបញ្ញត្តិដ៏ប្លែកក្នុងការឲ្យអភ័យដល់ជីវិតគោក្របីនេះ ឈ្មោះថាជាឧត្តមគតិដ៏ខ្ពស់បំផុត របស់រាជរដ្ឋាភិបាល ដែលគួរអ្នកប្រវត្តិសាស្ត្រចារិកកត់ត្រាទុក ក្នុងប្រវត្តិនៃប្រទេសកម្ពុជាតទៅ ។

ពណ៌នាអំពីអភ័យទានពិសេស សូមសន្មតថាចប់តែប៉ុណ្ណេះ ។

---

## ទុក្ខរបស់អ្នកក្រីក្រ

មុនបង្អស់ ការកើតមកជាទុក្ខក្រៃលែងទៅហើយ, តពីកើតមកមានតែទុក្ខកើតពីក្រីក្រ ទុគ៌តគ្រប់កាលទាំងពួង, តមកប្រព្រឹត្តចិញ្ចឹមជីវិតដោយការធ្វើជាខ្ញុំបំរើគេ ក៏ទុក្ខទៀត, ឧហ្ន៎ជីវិតនេះ មានតែទុក្ខត្រួតលើទុក្ខត ៗ គ្នាយ៉ាងនេះទេតើ !

បញ្ញត្រ:

# បញ្ញាសជាតក

## ភាគទី ៣

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព. ស. ២៤៨៦, គ. ស. ១៩៤៣

(តមក)

---

## អាទិត្តរាជជាតក ទី ១២

លោកអាចារ្យ ឈឹម - ស៊ុម ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

---

សទ្ធាយ ទានំ ទទតោតិ ឥទំ សត្ថា ជេតវនេ, វិហរន្តោ ទានបារមឹ អារព្ភ កថេសិ ។

*សត្ថា រីអង្គសម្តេចព្រះបរមសព្វជ្ញសាស្តាចារ្យ កាលទ្រង់សម្រាន្តព្រះឥរិយាបថនៅវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធនូវទានបារមី ទ្រង់សំដែងធម៌ទេសនាមានបទព្រះបាលីថា សទ្ធាយ ទានំ ទទតោ ដូច្នេះជាដើម ។*

*សេចក្តីដំណាលថា មានកាលសម័យថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងសាលាធម្មសភា ពោលពណ៌នាសរសើរទានបារមីនៃសម្តេចព្រះបរមសាស្តាថា ឧហ្ន ! អាវុសោទាំងឡាយ, ព្រះសាស្តាមិនថ្នាក់ក្នុងការឲ្យទានសោះ ។ កាលនោះ ព្រះសាស្តាទ្រង់ព្រះសវនាការឮសំដីភិក្ខុទាំងនោះដោយទិព្វសោត ក៏ទ្រង់ចេញចាកគន្ធកុដីមកកាន់*

សះលាធម្មសភា ទ្រង់គង់លើព្រះពុទ្ធាសនៈដ៏បវរ ហើយសួរភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ, ឥឡូវនេះអ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយអំពីរឿងអ្វី? ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសព្វសេចក្ដី, ព្រះជិនស្រីក៏ទ្រង់មានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ តថាគតជាបុគ្គលមិនផ្អែតក្នុងការឲ្យទានក្នុងកាលឥឡូវនេះមិនជាការអស្ចារ្យទេ, បើកាលពីដើម ទើបអស្ចារ្យខ្លាំង;" ទ្រង់ត្រាស់ប៉ុណ្ណោះហើយ ក៏គង់ស្ងៀមព្រាងើយកន្ទើយ ដរាបតែភិក្ខុទាំងនោះអារាធនា ទើបសម្ដេចព្រះភគវាទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា

អតីតេ ភិក្ខវេ ជេតុត្តរនគរេ អាទិត្តរាជា នាម រជ្ជំ ការេសិ

ម្នាលភិក្ខុទាំងឡាយ កាលកន្លងរំលងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទអាទិត្តរាជ សោយរាជសម្បត្តិក្នុងនគរជេតុត្តរ មានព្រះអគ្គមហេសីព្រះនាមនាងសុទ្ធទេវី ។ ព្រះរាជាអង្គនោះ ទ្រង់សោយរាជ្យប្រកបដោយធម៌ ទ្រង់ឲ្យជាងកសាងសាលាទាន ៦ ខ្នង គឺនៅក្បែរទ្វារនគរ ៤ ខ្នង នៅទីពាក់កណ្ដាលនគរ ១ ខ្នង ទៀបទ្វារព្រះរាជនិវេសន៍ ១ ខ្នង ហើយទ្រង់ចំណាយព្រះរាជទ្រព្យមួយសែនកហាបណៈព្រះរាជទានដល់ស្មូមយាចក អ្នកកំសត់ទុគ៌តរាល់ៗថ្ងៃ; ទ្រង់ផ្ញើនូវអ្នកជម្ពូទ្វីបទាំងអស់ ឲ្យក្បែរនង្គ័លទុកមិនបាច់ភ្ជួររាស់, ទ្រង់បង្អុរចុះនូវភ្លៀងគឺទាន ដូចជាមហាមេឃបង្អុរចុះនូវទឹកភ្លៀងក្នុងកាលនៃកត្តិកបុក្ស ទ្រង់រក្សាសីលមិនដែលឲ្យអ្នកណាមួយសម្លាប់សត្វ សូម្បីតែមួយឡើយ ។ ក្នុងកាលបច្ចូសសម័យថ្ងៃមួយ ព្រះរាជាទ្រង់ព្រះសុបិននិមិត្ត

ឃើញថា មានព្រាហ្មណ៍ចាស់ម្នាក់ មកសូមភោជន; លុះទ្រង់តើន ចាកក្រឡាបន្ទំឡើង ទ្រង់ជ្រាបថា ថ្ងៃនេះមុខជាមានស្មូមយាចកមក ពីព្រឹកមិនខាន, ទើបទ្រង់ព្រះចិន្តនាការគិតថា បើមាននរណាមួយមក សូមបេះដូង, អាត្មាអញគួរតែចំលាយទ្រូងយកបេះដូងមកឲ្យ; បើសូម ក្បាល, អាត្មាអញគួរតែកាត់ក្បាលឲ្យ; បើសូមភ្នែកក្តី សាច់ក្តី ឈាមក្តី សរីរៈពាក់កណ្ដាលក្តី, សរីរៈទាំងមូលក្តី, អាត្មាអញគួរតែឲ្យអវយវៈ ទាំងនោះ មិនត្រូវរា, ពុំនោះសោតទេ, បើនរណាមួយ សូមភរិយាក្តី ព្រះរាជបុត្រក្តី រាជសម្បត្តិក្តី, អាត្មាអញក៏គួរតែឲ្យ, ឬក៏ស្មូមយាចក ណាមួយមកនិយាយថា "បពិត្រព្រះបាទអាទិត្តរាជ, សូមព្រះអង្គមកជា ទាសៈខ្ញុំចុះ" ដូច្នេះក្តី, ក៏អាត្មាអញស៊ូលង់លោមអាត្មាអញទៅធ្វើខ្ញុំ បំរើអ្នកនោះជាប្រាកដ ។ កាលព្រះបាទអាទិត្តរាជកំពុងទ្រង់ព្រះ ចិន្តនាការដូច្នេះ ក៏ផែនក្រឡាមហាប្រថពី ដែលមានកម្រាស់២សែន ៤ ម៉ឺនយោជន៍ ក៏ក្រើករំពើកខ្ទរខ្ទារញាប់ញ័រឃ្លេងឃ្លោង ដូចជាដំរីចុះប្រេង ស្រែកកង្គួចបញ្ចេញសម្លេងខ្ទរខ្ទារ, ទាំងស្ដេចភ្នំសិនេរុបពិតរាជ ក៏ពុំ អាចតាំងនៅនឹងបាន មានអាការទន់ល្វន់ល្វាសទុនលំទោនមកកាន់នគរ ជេតុត្តរដូចជាចុងដំបងទងឆ្ពៅ ដែលបុគ្គលពេលក្លើង, ទាំងសមុទ្ទសាគរ ក៏កើតរលកបោកបែកផ្កាត្រែង. ផ្គរបន្ទោរក៏បញ្ចេញសូរ្យសែងឡៀល ភ្លាត់ប្រាក់សព្វទិសទី, ទាំងស្ដេចទេពកោសិយក៏ទះដៃឲ្យសព្វសាធុការ ជាមួយនឹងទេវតាទាំងពួង, ទាំងមហាព្រហ្មក៏ធ្វើសាធុការដែរ, កោលា-

ហាលកើតមានរហូតដល់ព្រហ្មលោក ។ ព្រោះហេតុនោះ បាន ជាព្រះសាស្តាទ្រង់ត្រាស់ថា

យទាហំ ទារកោ ហោមិ ជាតិយា អដ្ឋវស្សិកោ
តទា និសជ្ជ បាសាទេ ទានំ ទាតុំ វិចិន្តយឹ
ហទយំ ចក្ខុ ទទេយ្យំ មំសំ បិ រុធិរំ បិ ច
ទទេយ្យំ យទិវា កោចិ យាចេយ្យ អឌ្ឍសរីរំ
ឯវំ មេ ចិន្តយន្តស្ស អកម្បិ មហាបឋវី ។

កាលដែលតថាគតនៅជាកុមារ មានអាយុ ៨ ឆ្នាំតាំងពីកំណើត តថាគតអង្គុយលើប្រាសាទរំពឹងគិតចង់ឲ្យទានថា អញគួរតែឲ្យបេះដូង ឲ្យភ្នែក ឲ្យសាច់ ឲ្យឈាមទៅជាទាន, បើមានជនណាមួយ សូមសរីរពាក់កណ្ដាលក្ដី, ក៏អាត្មាអញគួរតែឲ្យ; កាលតថាគតកំពុងគិតយ៉ាងនេះ ក៏មហាប្រថពីកក្រើករំពើកញាប់ញ័រឡើង ។

ខណៈនោះឯង ពិភពសក្កទេវរាជ ក៏សំដែងនូវការក្ដៅសាយ ៗ ឡើង ។ ព្រះឥន្ទទ្រង់អាវជ្ជនាការពិចារណាថាជាហេតុនោះហើយ ក៏ទ្រង់ព្រះចិន្តនាការគិតថា ' ខ្ញុំ! ទាវបុគ្គលជាទីពឹងរបស់សត្វលោកកើតឡើងក្នុងលោកហើយតើ, ជានរកមុខជាទីងសូន្យ, ទេវលោកមុខជាទីងពេញមិនខាន, ព្រោះព្រះបាទអាទិត្តពជជាពន្លកពុទ្ធរបណ្ដាលពោធិសត្វ កំពុងតែចង់បំពេញព្រះពុទ្ធទាន, ឥឡូវនេះ គួរតែអាត្មាអញជួយបំពេញ

ព្រះបាទមីព្រះអង្គ, កាលពីដើមអាត្មាអញសូមវត្ថុដទៃ ៗ, ឥឡូវនេះ អាត្មាអញសូមភោជនចុះ" លុះទ្រង់រំពឹងគិតដូច្នោះ ក៏មានសេចក្ដីត្រេកអររីករាយជាសោមនស្ស ហោះចុះចាកឋានសួគ៌មកនិម្មិតខ្លួនជាព្រាហ្មណ៍ចាស់ មានសរីរៈស្គម សក់ស្កូវ កាន់ឈើច្រត់ដើររញីលរញ៉ែរ ចូលមកកាន់ព្រះរាជធានីហើយបង្ហាញខ្លួនដល់ព្រះបាទអាទិត្យរាជ ឲ្យទ្រង់ទតឃើញនៅក្នុងទីព្រះរាជលាន បានពោលនូវជយសព្ទ ៣ ដងថា ជយតុ ភវំ ជយតុ ភវំ មហារាជ ! បពិត្រព្រះរាជសម្ភារ, សូមព្រះករុណាទ្រង់មានជយជំនះ ! សូមព្រះករុណាទ្រង់មានជ័យជំនះ ! ។ គ្រានោះ ព្រះរាជាទ្រង់មានព្រះរាជឱង្ការត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកមកដើម្បីអ្វី? ។ ព្រាហ្មណ៍ក៏ក្រាបបង្គំទូលព្រះបក្រឹថា បពិត្រព្រះរាជសម្ភារ, ទូលព្រះបង្គំជាខ្ញុំចាស់ជរាគ្រាំគ្រាជាទុព្វលភាព ទ័លក្រដុនដាប ឥតមានវត្ថុអ្វីគ្រាន់ទទួលព្រះរាជទាន ឲ្យមានជីវិតតទៅទៀតសោះ, មិនតែប៉ុណ្ណោះ ថែមទាំងមានរោគឈឺពោះ ចុះរុះចុកសៀតព្យាធិបៀតបៀនជាច្រើនប្រការទៀតផង; ទូលព្រះបង្គំជាខ្ញុំមកដោយបំណងចង់សូមភោជន គ្រាន់ជាស្បៀងលៀងជីវិត សូមព្រះបពិត្រទ្រង់ព្រះរាជទាន ដល់ទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ ។ ព្រះរាជាទ្រង់ព្រះសវនាការហើយទ្រង់មានសេចក្ដីសោមនស្ស ដូចជាបុរសកំសត់ពីកំណើត បាននូវផ្ទាំងកំណប់, ទើបព្រះបមកតទ្រង់ក្រោកឡើងម្នីម្នា ព្រះហត្ថកាន់ភោជនដោយភាជនមាស ត្រាស់ថា "ម្នាលព្រាហ្មណ៍ដ៏ចំរើន, យើងឲ្យទានដល់អ្នកនេះ មិនមែនប្រាថ្នាសម្បត្តិស្ដេចចក្រពត្តិ មិនប្រាថ្នាសម្បត្តិ

ព្រះឥន្ទ្រ សម្បត្តិព្រះព្រហ្ម សម្បត្តិព្រះបច្ចេកពុទ្ធឡើយ, ទាននេះ សូមឲ្យបានជាបច្ច័យនៃការត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ" ហើយទ្រង់ ទូលនូវភោជនដូចជាទិព្វលើព្រះសិរៈរបស់ព្រះអង្គ ទើបទ្រង់ព្រះរាជទាន ដល់ព្រាហ្មណ៍ ។ គ្រានោះ ព្រាហ្មណ៍ក៏គវែងភោជនហោល ហើយ ពោលពាក្យទ្រគោះថា "យើអើ ព្រះបាទអាទិត្តរាជម្តេចក៏ឲ្យភោជនសៅ ហ្មងដល់យើងយ៉ាងនេះ!" ហើយក៏ធ្វើដូចជាខឹងណាស់ ភោគប្រាស់ ប្រទេចផ្កាសា ចៀសចេញទៅ ។ ព្រះមហាក្សត្រទុកជាឮសំដីដូច្នោះ ក៏ទ្រង់ឥតមានព្រះពិរោធក្រេវក្រោធដល់បន្តិចសោះ មានព្រះភក្រ្តស្រស់ បស់ញញឹមប្រិមប្រិយ ដូចសុវណ្ណបទុមកំពុងរីកស្គុះស្គាយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលព្រះសាស្តាទ្រង់ប្រកាស សេចក្តីនោះ ទ្រង់ត្រាស់ជាបទព្រះគាថា ដូច្នេះថា

សទ្ធាយ ទានំ ទទតោ ភោជនំ ទិព្វសម្បត្តិ
ព្រាហ្មណស្ស អទា ទានំ ពោធិយាយេវ ការណា
ទទាមិ ភោជនំ ទានំ ព្រាហ្មណោ កោធមានសោ
បហាយ ភោជនញ្ចេវ រាជា អកោធមានសោ
រាជា បសន្នចិត្តោវ សម្មោធិកាមកោ ភវេ
ព្រាហ្មណស្ស អទា ទានំ សម្ពោធិ បាបុណិស្សតិ ។

កាលដែលតថាគតឲ្យទានដោយសទ្ធា តថាគតបានឲ្យភោជន ដូចជាទិព្វ ជាទានដល់ព្រាហ្មណ៍ ព្រោះហេតុតែចង់បាននូវ

ពោធិញ្ញាណ, ព្រាហ្មណ៍ក៏ត្រឡប់ជាមានចិត្តខឹងក្រោធ លះបង់ចោលនូវភោជននោះទៅវិញ, តថាគតជាស្តេចឥតមានសេចក្តីក្រោធ មានចិត្តជ្រះថ្លាហើយ ជាអ្នកប្រាថ្នានូវពោធិញ្ញាណ បានឲ្យទានដល់ព្រាហ្មណ៍ ទើបដល់នូវសម្មាសម្ពោធិញ្ញាណពិតមែន ។

គ្រានោះ ព្រះមហាក្សត្រទ្រង់រំពឹងគិតដោយកម្លាំងព្រះបីតិសោមនស្សថា "ឱ ហ្ន៎ ធ្វើម្តេចអេះនឹងមានសុំយាចកមកដល់ទៀត !" ហើយទ្រង់គង់ចាំមើលផ្លូវ ដោយព្រះរាជហឫទ័យចង់ព្រះរាជទានណាស់ ដូចជាអ្នកប្រមឹកស្រាកំពុងស្រេកខ្លាំងដូច្នោះ ។ ខណៈនោះ សក្កទេវរាជក៏លះបង់ភេទព្រាហ្មណ៍ចាស់ ប្រែក្រឡះជាព្រាហ្មណ៍កំឡោះវិញ, ព្រាហ្មណ៍នោះមិញមានរូបល្អ មានសម្បុរស្រស់ ត្រឡប់ចូលមកជិតព្រះរាជា ធ្វើអាការពក់ទាក់ ក្រាបបង្គំទូលសួរព្រះរាជាថា

កច្ចិ នុ ភោតោ កុសលំ កច្ចិ នុ ភោតោ អនាមយំ
កច្ចិ ជិតោ ជនបទោ កច្ចិ វុឌ្ឍិ ន ឆិជ្ជតិ

បពិត្រព្រះរាជសម្ភារ ដ៏ទ្រង់នូវព្រះចេស្តា, ព្រះករុណាទ្រង់ប្រកបដោយព្រះបរមសុខស្រួលក្នុងព្រះអង្គទេឬ? ព្រះករុណាពុំមានរោគអាពាធព្យាធិអ្វី មកបៀតបៀនព្រះអង្គកាយទេឬ? ព្រះករុណាទ្រង់ចាត់ការរៀបចំជនបទខែត្រដែន បានសេចក្តីស្ងប់ស្រួលទេឬ? ភ្លៀងរលឹមធ្លាក់មក

ពុំដាច់ ល្មមសម្រេចផលក្សេត្រកម្មនៃអ្នកជនបទបានទេឬ ៗ ព្រះរាជាទ្រង់ត្រាស់ថា

កុសលញ្ចេវ មេ ព្រហ្មេ   អថោ ព្រហ្មេ អនាមយំ
អថោ ជិតោ ជនបទោ   អថោ វុដ្ឋិ ច និជ្ជតិ

"ម្នាលព្រាហ្មណ៍, យើងមានសេចក្ដីសុខស្រួលក្នុងកាយទេ, ពុំមានពេគអាពាធព្យាធិអ្វីបៀតបៀនទេ, ទាំងជនបទ ក៏យើងចាត់ការរៀបចំបានសេចក្ដីស្ងប់ស្រួលដែរ,ម្យ៉ាងទៀតភ្លៀងលើមធ្លាក់មកពុំដាច់ ល្មមសម្រេចផលក្សេត្រកម្មនៃអ្នកជនបទបាន" ហើយទ្រង់ត្រាស់តទៅទៀតថា

ស្វាគតន្តេ មហាព្រហ្មេ   អថោ តេ អទុរាគតំ
អន្តោ បវិស ភទ្ទន្តេ   បាទេ បក្ខាលយស្សុ តេ

ម្នាលមហាព្រាហ្មណ៍, អ្នកអញ្ជើញមកប្រពៃហើយ ! ម្យ៉ាងទៀត អ្នកទើបនឹងមកដល់ថ្មីៗ អម្បាញ់មិញនេះ បើដូច្នេះ ចូរអ្នកដំណើរ ចូលមកយកទឹកលាងជើងឲ្យស្រួលបួលសិនចុះ ៗ

លុះព្រះមហាសត្វទ្រង់ត្រាស់ដូច្នេះហើយ   ទ្រង់ព្រះចិន្តនាការគិតថា "ព្រាហ្មណ៍នេះមិនមែនជាមកដោយឥតការណ៍ទេ, គួរតែអាត្មាអញសួរឲ្យដឹងដើមទង" ទើបទ្រង់ត្រាស់ព្រះរាជឲ្យការសួរថា

អ្នកឯងមានការណ៍ដូចម្ដេច មានហេតុយ៉ាងណា បានជាមក

ដល់ដែនយើង? យើងសួរអ្នក ត្រូវតែអ្នកប្រាប់យើងតាមត្រង់ កុំខាន ។

ព្រាហ្មណ៍បានស្តាប់ព្រះឱង្ការនោះ ហើយក្រាបបង្គំទូលតបថា បពិត្រព្រះរាជសម្ភារ ខ្ញុំព្រះអង្គមកដើម្បីសូមព្រះនាងសន្ធទេវីជាព្រះរាជ-ទេពីរបស់ព្រះអង្គ; សូមព្រះអង្គព្រះរាជទាន ព្រះនាងដល់ទូលព្រះបង្គំជាខ្ញុំកុំខាន ហើយក្រាបបង្គំទូលដូច្នេះទៀតថា

ធម្មតាព្រែកស្ទឹងបឹងទន្លេមេខុទកវារី ជាទីពេញព្រៀបដោយទឹកថ្លា អស់ពួកមហាជនមនុស្សម្នា ព្រមទាំងសត្វទ្វេបាទ បតុប្បាទ តែងសង្វាតចូលមកទទួលព្រះរាជទាន ចុះផឹក ជម្រះប្រាណកំសាន្តបំបាត់សេចក្តីស្រេកឃ្លានគ្រប់ៗគ្នា ក៏ដល់ធារពុំដែលស្រកស្រុតរីងស្ងួតទៅឡើយ ដូចម្តេចមិញ; ឯព្រះរាជហឫទ័យរបស់ព្រះអង្គ ក៏ពេញដោយសេចក្តីមេត្តាអាសូរករុណាដូច្នោះ; ទូលព្រះបង្គំជាខ្ញុំមកសូមហើយ, សូមទ្រង់ព្រះរាជទានព្រះអគ្គមហេសី ដល់ទូលព្រះបង្គំជាខ្ញុំកុំខាន ។

ព្រះមហាសត្វទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ មានព្រះសោ-មនស្សរីករាយឥតក្រៃក្រោធខឹងពាក្យព្រាហ្មណ៍នោះឡើយ ហើយមានព្រះរាជហឫទ័យមិនរួញរាកក្នុងការបរិច្ចាគទាន ទ្រង់បន្ទូលព្រះវាចាត្រាស់ដូច្នេះថា

ម្នាលព្រាហ្មណ៍ អ្នកឯងសូមរបស់អ្វីនឹងយើង យើងឲ្យរបស់

នោះ, យើងមិនធុញទ្រាន់ទេ, យើងមិនលោភក់របស់ដែលមាន ទេ, ព្រោះចិត្តយើងតែងរីករាយចំពោះការឲ្យដូច្នោះស្រាប់ ។

ទ្រង់ត្រាស់ដូច្នេះហើយទ្រង់ឆាកទតព្រះរាជទេវីត្រាស់ថា ហៃប្អូនពុំងា, បងចង់បានសម្ភាសម្ភោជញ្ញាណណាស់ ។ ព្រះរាជទេវីទ្រង់ព្រះសវនាការស្តាប់ព្រះរាជឱង្ការនោះហើយ ទ្រង់មិនមានសេចក្តីភ័យភិតត្រាស់ព្រះរាជសវនីយថា បពិត្រព្រះរាជសម្ភារ, ខ្ញុំម្ចាស់ជាទាសីរបស់ព្រះអង្គស្រាប់, ព្រះអង្គជាព្រះរាជស្វាមីជាធំលើខ្ញុំម្ចាស់ហើយ, បើព្រះអង្គសព្វព្រះរាជហឫទ័យចង់ព្រះរាជទានរបស់អ្វី សូមទ្រង់ព្រះរាជទានកុំទើសទាល់, ខ្ញុំម្ចាស់ឥតភ័យបារម្ភឡើយ, បពិត្រព្រះសម្មតិទេព, សូមព្រះអង្គអនុគ្រោះ សូមទ្រង់អត់ទោសកំហុសដល់ខ្ញុំម្ចាស់, ខ្ញុំម្ចាស់សូមថ្វាយបង្គំចំពោះព្រះបាទ, ការថ្វាយបង្គំរបស់ខ្ញុំម្ចាស់នេះ ជាទីបំផុតហើយ ។ ព្រះមហាសត្វក៏ទ្រង់កាន់យកទឹកកុណ្ឌីដែលប្រទាននាងទេវីដល់ព្រាហ្មណ៍មួយរំពេចថា "ម្នាលព្រាហ្មណ៍, នាងសន្ធទេវីជាទីស្រឡាញ់ ជាទីពេញចិត្តរបស់យើង, ប៉ុន្តែសព្វញាតញាណ ជាទីស្រឡាញ់ពេញចិត្តជាងនាងសន្ធទេវី ១ រយគុណ ១ ពាន់គុណទៅទៀត" ត្រាស់ដូច្នេះហើយ ក៏ប្រទាននាងទេវីទៅព្រាហ្មណ៍នោះ ។ ខណៈនោះ ផែនប្រឹថពីកក្រើករំពើកញាប់ញ័រ ទាំងមហាសមុទ្រក៏កើតព្យុះរលកបោកបែកផ្កាត្រែង, ទាំងស្តេចភ្នំសិនេរុ ក៏ឱនលំទោនមក, ទេវតានឹងមហាព្រហ្មទាំងឡាយ ឲ្យសព្ទសាធុការទ្រហឹងអឺងកង កើតជាកោលាហលដរាបដល់ព្រហ្មលោក ។

តេន វុត្តំ ព្រោះហេតុនោះបានជា សម្តេចព្រះបរមពិជិតមារ ទ្រង់ត្រាស់សំដែងថា

កាលដែលតថាគតកើតជាព្រះបាទអាទិត្តរាជនោះ បានចាប់
ដៃនាងទេវី កាន់កុណ្ឌីទឹកជ្រួចឲ្យទៅជាទានដល់ព្រាហ្មណ៍
ព្រោះបង់បានត្រាស់ពោធិញាណ, កាលតថាគតលះបង់
នាងទេវីគ្រានោះ ក៏កើតសេចក្ដីអស្ចារ្យគួរខ្លាច គួរព្រឺរោម
ព្រឺស្បែក ទាំងផែនដីក៏កក្រើករំពើកញាប់ញ័រ ៗ

គ្រានោះ ព្រះឥន្ទ្រចាប់សក់នាងទេវីហើយកន្ត្រាក់នាំចេញទៅ ។ ព្រះនាងទេវីក៏ទ្រង់ព្រះកន្សែង សោកវិយោគខ្សឹកខ្សួលអួលអក់ក្នុងព្រះឧរា ៗ មហាសត្តោ តំ ទិស្វា ព្រះមហាសត្វទ្រង់ទតឃើញដូច្នោះ ទ្រង់មានព្រះរាជឱង្ការលួងលោមថា ហៃប្អូនមាសពុំអា, សូមប្អូនស្ងួនភ្ងា នាងកុំខ្សឹកខ្សួលឡើយ, បងសូមសមាសពោធិញាណនឹងនាងឯងហើយ សូមប្អូនអាណិតបងចុះ ៗ ព្រះនាងទេវីទ្រង់ព្រះសណ្ដាប់ព្រះរាជឱង្ការ ហើយមានព្រះរាជសវនីយថា បពិត្រមហារាជបរមកស្ដា, ខ្ញុំម្ចាស់សូមថ្វាយសព្វញ្ញុតញាណចំពោះព្រះអង្គ, សូមទ្រង់កុំព្រួយព្រះរាជហឫទ័យឡើយ ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្តេចព្រះបរមសាស្តាចារ្យ កាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ថា

នាកាលព្រះបរមពោធិសត្វ ទ្រង់ព្រះរាជទានព្រះទេពីស្រេច
ព្រាហ្មណ៍កំណាចមានចិត្តក្រេវក្រោធ ហើយអូសយកទៅ

ឯព្រះរាជាព្រះអង្គមានព្រះរាជហឫទ័យមិនក្រេវក្រោធ ប្រកប
ដោយសេចក្ដីទៀងទាត់ ព្រោះព្រះទ័យប្រាថ្នាតែព្រះ
សម្ពោធិញ្ញាណ ។

គ្រានោះ ព្រះឥន្ទ្របានជ្រាបអធ្យាស្រ័យនៃក្សត្រទាំងពីរព្រះអង្គ
ក៏ទ្រង់ពោលសរសើរសព្វគ្រប់ប្រការដល់ព្រះអង្គ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្ដេចព្រះបរមសាស្ដាចារ្យ
កាលទ្រង់ប្រកាសនូវសេចក្ដីនោះ ទ្រង់ត្រាស់ថា

សម្ដេចព្រះសក្កទេវិន្ទ ទ្រង់ជ្រាបនូវគំរិះនៃក្សត្រទាំង ២
ព្រះអង្គនោះហើយ ទ្រង់ពោលសរសើរថា សត្រូវទាំងឡាយ
ទាំងពួង ទោះបីជាទិព្វក្ដី រាមនុស្សក្ដី, ក៏ព្រះអង្គមាន
ជ័យជំនះឈ្នះសព្វគ្រប់ប្រការ ទាំងមហាប្រឹថពីព្រះអង្គ
បានធ្វើឲ្យញាប់ញ័រ កិត្តិស័ព្ទសេចក្ដីសរសើរចំពោះព្រះអង្គ
ផ្សព្វផ្សាយទៅរហូតដល់ឋានតាវត្តិង្ស ទាំងផ្គរបន្ទរក៏ជួប
ជាលង្វៀលប្រាក់ ទៅជុំវិញសព្វទិសប្រាកដដល់ក្នុងទាំង
ឡាយ, ក្នុងនាទេបពិតទាំងពីរ ក៏អនុមោទនាចំពោះព្រះអង្គ,
ពួកទេវតាទាំងអស់ ទោះទាំងព្រះឥន្ទទាំងព្រះព្រហ្មទាំងស្ដេច
បជាបតិ ទាំងព្រះចន្ទ្រ ទាំងព្រះយម ទាំងស្ដេចវេស្ស-
វណ្ណក្ដី តែងអនុមោទនាសរសើរថា ព្រះបាទកាទិត្តរាជ
អង្គនោះ ទ្រង់ធ្វើនូវអំពើដែលអ្នកផងធ្វើបានដោយក្រម,
សប្បុរសឲ្យទានដែលគេឲ្យផងបានដោយក្រម, ធ្វើនូវអំពើល្អ

ដែលគេប្រព្រឹត្តផងកើត, អសប្បុរសទាំងឡាយ ធ្វើតាមផង ពុំបានទេ, ធម៌របស់សប្បុរស ពួកអសប្បុរសប្រព្រឹត្ត បានដោយក្រ, ព្រោះហេតុនោះ បានជាដំណើរចេញអំពី លោកនេះទៅកាន់លោកខាងមុខ នៃសប្បុរសនឹងអសប្បុរស ទាំងឡាយជាគតិផ្សេងគ្នា គឺពួកអសប្បុរសតែងទៅកាន់នរក ពួកសប្បុរសតែងទៅកាន់ឋានសួគ៌ ។

គ្រានោះ មហាសត្វទ្រង់មានព្រះរាជហឫទ័យពេញដោយបីតិ ដោយព្រះតម្រិះយល់ថា ទានដែលអាត្មាអញឲ្យនេះជាទានប្រពៃពេក ណាស់ ។ លំដាប់តពីនោះមក ព្រះឥន្ទ្រក្រាបបង្គំទូលថា បពិត្រ មហារាជ, ទ្រង់ទាំងពីរព្រះអង្គមានព្រះទ័យដូចគ្នាតែមួយបែប, តទៅ ក្នុងកាលជាខាងក្រោយ ទ្រង់នឹងបានត្រាស់ជាព្រះពុទ្ធពុំខាន; បពិត្រ ព្រះសម្មតិទេព, ខ្ញុំជាសក្កទេវរាជ មកដោយសេចក្ដីសុចរិតចំពោះ ព្រះអង្គ ។ ព្រះឥន្ទ្រាធិរាជពោលដូច្នេះហើយ ក៏សូមឲ្យព្រះរាជា ទ្រង់ព្រះរាជទានអភ័យទោស ទើបថ្វាយព្រះនាងសន្ធទេវីចំពោះព្រះ រាជាវិញថា

ខ្ញុំព្រះអង្គសូមថ្វាយព្រះនាងទេវី ដ៏ល្អល្អះសព្វគ្រប់ឥន្ទ្រិយ ចំពោះ ព្រះអង្គវិញ, សូមព្រះអង្គតាំងព្រះរាជហឫទ័យស្រឡាញ់ព្រះ នាងទេវី ទាំងព្រះនាងទេវីក៏សូមតាំងព្រះរាជហឫទ័យស្រ- ឡាញ់ព្រះបក្រីកុំបីមានអាក់ ៗ ធម្មតាទឹកដោះនឹងស័ង្ខ រត ទាំងពីរមុខនេះ មានពណ៌ស្មើគ្នាយ៉ាងណា, ក៏សូមឲ្យព្រះ

ករុណានឹងព្រះនាងទេវី មានព្រះរាជហឫទ័យស្មើគ្នាយ៉ាងនោះ
ចុះ, ខ្ញុំព្រះអង្គជាសក្កទេវិន្ទ មកក្នុងសំណាក់ព្រះអង្គ សូម
ផ្គងអញ្ជលីចំពោះព្រះអង្គ, បពិត្រព្រះអង្គជាស្តេចប្រសើរ
ខ្ញុំព្រះអង្គសូមថ្វាយបង្គំ, បពិត្រព្រះអង្គមានព្យាយាមធំ, ល្អ
ហើយ! ប្រពៃហើយ! ព្រះអង្គពិតជានឹងបានត្រាស់ជា
សម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ក្នុងកាលជាអនាគតពុំ
ខាន ។

ព្រះឥន្ទ្រាធិរាជពោលដូច្នេះហើយ ទ្រង់ពោលទូន្មានតទៅទៀតថា
បពិត្រមហារាជ, សូមព្រះអង្គប្រព្រឹត្តធម៌គោរពចំពោះព្រះ
វររាជមាតាបិតា; បពិត្រព្រះរាជា, ព្រះអង្គប្រព្រឹត្តធម៌ក្នុង
លោកនេះហើយ នឹងបានទៅកាន់ស្ថានសួគ៌; បពិត្រព្រះ
មហារាជ, សូមព្រះអង្គប្រព្រឹត្តធម៌ គឺសេចក្តីមេត្តាប្រោស
ប្រណីចំពោះពួកសត្វពាហនៈ នឹងពួកពលគ្រប់គ្នា; បពិត្រ
ព្រះរាជា. ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយនឹងបាន
ទៅកាន់ឋានសួគ៌, បពិត្រមហារាជ, សូមព្រះអង្គប្រព្រឹត្ត
ធម៌ ចំពោះម្រឹគបក្សីសព្វសត្វ, បពិត្រព្រះរាជា ព្រះ
អង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ ទ្រង់នឹងបានទៅកាន់
ឋានសួគ៌, បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ព្រោះ
ថា ធម៌ដែលព្រះអង្គសន្សំហើយ រមែងនាំមកនូវសេចក្តី
សុខ; បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោក

នេះហើយ ទ្រង់នឹងបានទៅកាន់ឋានសួគ៌, បពិត្រព្រះមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះព្រះវន្ទនឹងទេវតានឹងព្រហ្មទាំងឡាយ, ជនទាំងឡាយដល់នូវឋានត្រៃត្រឹងដោយការសន្សំធម៌, ព្រោះហេតុនោះ សូមព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ ។

ព្រះឥន្ទ្រាធិរាជ ទ្រង់ប្រៀនប្រដៅទសពិធរាជធម៌យ៉ាងនេះហើយ ទ្រង់ទូន្មានតទៅទៀតថា "បពិត្រមហារាជ, សូមព្រះអង្គកុំប្រហែសធ្វេស, សូមទ្រង់ឲ្យទាន, សូមទ្រង់រក្សាសីលកុំបោះបង់ឡើយ" ពោលទូន្មានដូច្នេះហើយ ក៏ត្រឡប់ទៅកាន់ទីលំនៅរបស់ព្រះអង្គវិញហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្តេចបរមសាស្តាចារ្យ ទ្រង់ប្រកាសនូវសេចក្តីនោះទ្រង់ត្រាស់ថា

សម្តេចព្រះមឃវាទេវរាជ ជាព្រះស្វាមីនៃនាងសុជាតា លុះទ្រង់ត្រាស់ដូច្នេះហើយ ក៏ពោលសរសើរព្រះបរមពោធិសត្វរួចស្រេចស្តេចហោះទៅកាន់ឋានទេវលោកវិញហោង ។

សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា សម្តេចព្រះបរមសាស្តាចារ្យទ្រង់នាំធម៌ទេសនានេះមកហើយ ទ្រង់ត្រាស់ព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ តថាគតបានឲ្យទានក្នុងកាលដែលនៅជាពោធិសត្វយ៉ាងនេះឯង" ហើយទ្រង់សំដែងប្រកាសសច្ចធម៌, លុះចប់សច្ចធម៌ ទ្រង់ប្រជុំជាតកថា

ព្រះវររាជមាតានៃព្រះបាទអាទិត្តរាជ ទ្រង់ចេរិលវិលមក បានមកកើតជាព្រះនាងមហាមាយា, ព្រះវររាជបិតា បានជាព្រះបាទសុទ្ធោទន, ព្រះឥន្ទ្រ បានជាព្រះអនុរុទ្ធ, នាងសន្ធទេវីបានជានាងយសោធរា, បរិសទ្យក្រៅពីនោះបានជាពុទ្ធបរិសទ្យទាំងអស់. ឯព្រះបាទអាទិត្តរាជគឺជាតួអង្គតថា-គតជាលោកនាថហ្នឹងឯង; អ្នកទាំងឡាយចូរទ្រទ្រង់ចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ អាទិត្តរាជជាតក ទី ១២ តែប៉ុណ្ណោះ ។

## ខ្ញុំគេថោកបំផុត

ឱភារតៈ! បានឮរឿង ៗ មកថា បុគ្គលឈ្មោះថាស្លាប់មាន ៥ ប្រការ សូម្បីរស់នៅក៏ឈ្មោះថា ស្លាប់ដែរ គឺបុគ្គលក្រីក្រ ១ បុគ្គលឈឺច្រើន ១ បុគ្គលល្ងង់ ១ បុគ្គលដែលគេនិរទេស ១ បុគ្គលដែលធ្វើជាខ្ញុំបំរើគេ ១ ។

ដោយភក្តិ ខ្ញុំបំរើគេមិនហ៊ានស៊ីតាមចិត្តឯងទេ នៅតែចាំថែរក្សាឥតបានដេកពួន មិនដែលនិយាយពាក្យណាម្តងដែលឥតខ្លាចក្រែងសោះ បើតែយ៉ាងនេះតើខ្ញុំបំរើគេនៅតែរស់បានទៀតហ្ន៎?

សេវាធម៌ (ធម៌ជាខ្ញុំបំរើគេ) លោកពោលទុកថាជាការប្រព្រឹត្តនៃឆ្កែ នេះបើយើងនិយាយដោយមិច្ឆាទិដ្ឋិ, តែក្នុងករណីនេះ សត្វឆ្កែតែងប្រព្រឹត្តធ្វើតាមឆន្ទនៃខ្លួន, ឯអ្នកបំរើគេ ធ្វើតាមបង្គាប់នៃជនដទៃជាម្ចាស់ ។

បញ្ចតន្ត្រៈ

## ផ្នែកអក្សរសាស្ត្រ

# រឿងសាមកុក

កណ្ឌទី ២០

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

( តមក )

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ទៀវពីនិយាយនឹងទៀវតាយ, អង់គុងថា កាលដែលយើងលើកទ័ពមកនោះ នឹងបានគិតប្រទូសរ៉ាយដល់មហាឧបរាជក៏ទេ ប្រយោជន៍ធ្វើការតបស្នងសងគុណមហាឧបរាជតែគ្រប់វេលាមិនដាច់ ក្រោយនោះគីមៅចិត្តអាក្រក់គិតប្រទូសរ៉ាយដល់យើងឲ្យអស់ជីវិត បានជាយើងសម្លាប់ជីវិតគីមៅវិញ មហាឧបរាជមិនដឹងថា គីមៅប្រទូសរ៉ាយនឹងយើងមុន បានជាឲ្យអ្នកឯងទាំង ២ នេះលើកកងទ័ពមកចាប់យើង ធម្មតាកើតមកជាមនុស្សក្តី សត្វក្តី រមែងស្រឡាញ់ជីវិតដូចគ្នាទាំងអស់ បើមានគេមកបៀតបៀនវេលាណា តែងតែការពារអន្តរាយដោយសេចក្តីស្រឡាញ់ខ្លួនដែលគួនអ៊ុំ, ទៀវហ៊ុយ បានធ្វើទុក្ខដល់អ្នកទាំង ២ នោះកុំបីមាន

អាឃាតព្យាបាទតទៅឡើយ ឥឡូវយើងអនុគ្រោះដោះឲ្យអ្នកទាំង ២ រូប អាយុជីវិត ឲ្យអ្នករិះគិតវិលត្រឡប់ទៅវិញចុះ ដើម្បីនឹងឲ្យដំណឹងដល់មហាឧបកជជ្រាបសេចក្ដី ហើយអ្នកត្រូវជួយនិយាយឲ្យឃើញសេចក្ដីពិតសុចរិតរបស់យើង ។ ក៏សុំចងមេត្រីដល់អ្នកទាំង ២ តទៅ ។

ឡៅតាយទឹងអងតុងបានស្ដាប់ឡៅពីអធិប្បាយដូច្នោះ ក៏មានសេចក្ដីត្រេកអរណាស់ឆ្លើយតបថា ដែលលោកប្រោសករុណាទុកអាយុជីវិតខ្ញុំបាទ ព្រះតេជៈព្រះគុណធ្ងន់នឹងរកអ្វីប្រៀបផ្ទឹមពុំស្មើដល់ ខ្ញុំបាទនឹងវិលត្រឡប់ទៅប្ដឹងផ្ដល់ពីខពជការដល់មហាឧបកជថា លោកមានចិត្តសត្យទៀងត្រង់ មិនបានគិតប្រទូសរ៉ាយដល់មហាឧបកជឡើយ ដែលបានជាធ្វើការហួសទៅហើយទាំងម្ល៉េះ ពីព្រោះសេចក្ដីទាល់លើទាល់ បើមហាឧបកជមិនជឿខ្ញុំបាទនឹងយកបុត្រភរិយាទុកជាចំណាំ បើអំណើះតទៅមុខ លោកប្រែចិត្តគិតប្រទូសរ៉ាយប្រការម្ដេច សុំឲ្យសម្លាប់បុត្រភរិយា ខ្ញុំបាទទាំងអស់ចុះ ។ ឡៅពីបានស្ដាប់ដូច្នោះក៏អស់សង្ស័យគំនាប់ឡៅតាយទឹងអងតុងតាមគួរសមហើយថា "ដែលអ្នកទទួលធុរៈយើងដូច្នេះ យើងអរគុណណាស់" ហើយឡៅពីក៏ប្រមូលទាហានដែលគៀរហ៊ុមបានមកនោះ បង្វិលឲ្យឡៅតាយ, អងតុងវិញ ។ ឡៅតាយអងតុងក៏គំនាប់លាឡៅពី នាំទាហានទាំងពួងចេញពីស្រុកឈើជីវ ចេញទៅប្រហែលចម្ងាយ ៥០០ សិន (២០ គ.ម.) ។

ខណៈកាលឡៅពីនិយាយលើកទោសឡៅតាយទឹងអងតុងនោះ, គៀរហ៊ុយក៏ក្ដៅក្ដួលធ្លូលក្នុងចិត្ត គិតលើកទាហានលបចេញទៅស្ទាក់

កណ្តាលផ្លូវ ។ គួនអ៊ូឃើញតៀវហ៊ុយលើកទាហានទៅកំសត់ហើយ ទើបឡើងសេះនាំទាហាន ៤ ៥ នាក់ តាមស្នាមជើងតៀវហ៊ុយទៅ ។ ឯតៀវហ៊ុយកាលគ្រឡេកឃើញឡេវតាយ អង់គុងលើកទាហានមក, តៀវហ៊ុយក៏កាន់ទួនទៅឈរស្កាត់ពីមុខ ហើយស្រែកគំហកដោយសំឡេងខ្លាំងថា ឯងនិយាយក្បត់កុហកបញ្ឆោតបងអញដូចម្តេចខ្លះ? បានជាបងអញលែងឯងទាំង ២ នាក់មក? ។ ឡេវតាយ, អង់គុងបានឮតៀវហ៊ុយស្រែកគំហកដូច្នោះ ក៏ភ័យស្លុតចិត្តញ័ររន្ធត់អស់ទាំងខ្លួន មិនបានតបថាប្រការម្តេចសោះ ទទួលគួនអ៊ូតាមទៅទាន់ឃើញតៀវហ៊ុយនៅស្កាត់ពីមុខដូច្នោះ ក៏ស្រែកថា តៀវហ៊ុយកុំអាលធ្វើវេរ បងយើងលែងគេឲ្យទៅហើយ ។ តៀវហ៊ុយឆ្លើយថា បើលែងអា ២ នាក់នេះទៅហើយ គង់តែវានឹងត្រឡប់មកធ្វើអន្តរាយដល់យើងវិញជាប្រាកដ ។ គួនអ៊ូតបថា បើគេមិនដឹងគុណហើយយើងនឹងត្រឡប់មកប្រទូសរ៉ាយយើងវិញ សឹមយើងចាប់សម្លាប់ចេញ គ្មានសេចក្តីខ្មាសទេ ។

ឡេវតាយ, អង់គុងបានស្តាប់ដូច្នោះក៏ឆ្លើយថា ពេលនេះឡេវពីមានគុណដល់យើងជាទម្ងន់ណាស់ ប្រសិនបើមហាឧបរាជប្រើយើងឲ្យលើកទ័ពមកទៀត យើងក៏មិនមកជាដាច់ខាត សូម្បីមហាឧបរាជនឹងសម្លាប់បុត្រភរិយាយើងទាំងអស់ក៏តាមចិត្តចុះ សូមអ្នកទាំង ២ បើកលែងយើងទៅតាមស្រួលកុំបីបៀតបៀនយើងឡើយ ។ តៀវហ៊ុយថា ក្បាលឯងទាំង ២ នាក់នេះ អញលើកទុកឲ្យនៅជាប់នឹងខ្លួនហើយ បើប្រសិនឯងទៅញុះញង់ចុះប្រការម្តេច ចូលនឹងលើកទ័ពមក អញនឹងកាប់ឯង

ព្រមទាំងទាហានឯងមិនឲ្យសល់ម្នាក់ ៗ ឡៀតាយទឹងអឹងតុងបានស្ដាប់ទាំងខ្លាចទាំងមានចិត្តត្រេកអរ ក៏បង្គំបរសេះនាំទាហានស្រូតរូតទៅ ៗ

គួនអ៊ូ, តៀវហ៊ុយក៏វិលត្រឡប់ទៅក្រុងឈីជីវវិញ ហើយជំរាបឡៀវពីថា ដែលលោកបើកលែងឡៀតាយទឹងអឹងតុងទៅនោះ ខ្ញុំបាទយល់ឃើញថា ចូឆូទឹងលើកកងទ័ពមកធ្វើអន្តរាយលោកវិញពុំខាន ៗ ស៊ុនខៀនបានឮគួនអ៊ូ, តៀវហ៊ុយថាដូច្នោះ ក៏និយាយទឹងឡៀវពីថា ដែលប្អូនលោកថានេះក៏ត្រូវមែនហើយ បើចូឆូលើកទ័ពមក លោកទឹងតាំងទ័ពនៅតែក្នុងស្រុកឈីជីវនេះ គង់ទឹងថ្លោះការព្រោះចូឆូជាប្រាកដ សូមឲ្យលោករំលែកពលទាហាន ទៅតាំងនៅក្នុងស្រុកសៀវផាយ ១ ក្នុងស្រុកហៃហ៊ី ១ កង ទឹងបានជួយច្បាំងជាទ័ពសន្ទប់ពីក្រៅ ៗ ឡៀវពីបានស្ដាប់យល់ឃើញត្រូវ ទើបប្រើគួនអ៊ូ ឲ្យលើកពលនាំនាងកាំហ៊ូយ៉ិនទឹងនាងប៊ីហ៊ូយ៉ិន ដែលជាភរិយាឡៀវពីទៅរក្សាទុកឯស្រុកហៃហ៊ី ប្រើស៊ុនខៀនទឹងតាន់យ៉ុង, ប៊ីតុក, ប៊ីហាង ៤ នាក់នេះទៅរក្សាស្រុកឈីជីវ ឯឡៀវពីទឹងតៀវហ៊ុយក៏លើកពលទាហានទៅរក្សាស្រុកសៀវផាយ ៗ

កាលឡៀតាយទឹងអឹងតុងទៅដល់ក្រុងហ៊ូតោ ក៏ចូលទៅជំរាបចូឆូតាមរឿងដែលបានទៅធ្វើសង្គ្រាមទឹងគួនអ៊ូ តៀវហ៊ុយនោះគ្រប់ប្រការ ហើយថា ឡៀវពីមានចិត្តសុចរិតគិតដល់គុណូបការមហាឧបរាជមិនដែលដាច់ មិនបានក្បត់ចិត្តគិតប្រទូសរ៉ាយដល់មហាឧបរាជក៏ទេ ដែលឲ្យគួនអ៊ូ តៀវហ៊ុយចេញមកច្បាំងទឹងខ្ញុំបាទនោះ ជាធម្មតាការពារជីវិតទេ

ឥឡូវឡៅតីបើកលែងខ្លួនខ្ញុំបាទទាំង ២ នាក់ ឲ្យចូលមកសារភាពក្តីដល់ មហាឧបរាជតាមផ្លូវរាជការជាសុចរិត ។

ចួចូបានស្តាប់ដូច្នោះក៏ខឹងណាស់ថា "អាទាហានទើបពីស្លាប់យ៉ាងនេះនឹងចិញ្ចឹមរក្សាទុកមិនបានទេ," ថាហើយក៏បង្គាប់ពេជ្ឈឃាតឲ្យចាប់ខ្លួនឡៅតាយនឹងអងតុងប្រុងនឹងឲ្យនាំទៅសម្លាប់ ។ ខុងយ៉ុងឃើញដូច្នោះក៏ចូលទៅឃាមឃាត់ចួចូថា ឯថ្វីដៃឡៅតាយនឹងអងតុងនោះ នឹងទៅតទល់នឹងថ្វីដៃសេចក្តីរិះគិតរបស់ឡៅតីនោះមិនបានទេ ដែលលោកមិនឲ្យយកខ្លួនអ្នកទាំង ២ ទៅប្រហារជីវិតចេញនោះ ទាហានទាំងឡាយនឹងធ្វើការតទៅក៏មានតែសេចក្តីតូចចិត្ត ។ ចួចូបានស្តាប់ក៏យល់ឃើញត្រូវដូចពាក្យខុងយ៉ុងថា, ទើបបង្គាប់ពេជ្ឈឃាតថាកុំឲ្យសម្លាប់ចុះ តែត្រូវឲ្យដកហូតងារចេញពីនាយទាហាន យកខ្លួនទៅទុកប្រើជារាស្ត្រសុទ្ធសាធ ។ រួចចួចូក៏កេណ្ឌប្រមូលសេនាទាហាននឹងលើកទៅតតាំងច្បាំងនឹងឡៅតី, ខុងយ៉ុងនិយាយថា "ដែលមហាឧបរាជនឹងលើកទ័ពទៅនោះ វេលានេះជាទេសកាលរងាពន់ពេក ទាហានទាំងពួងនឹងបានសេចក្តីលំបាកគោកយ៉ាក សុំឲ្យលោកចាត់ប្រើបំរើដែលមានសតិបញ្ញា ទៅនិយាយបញ្ចុះបញ្ចូលឡៅតៀវនឹងតៀវស៊ីវឲ្យឡើងមកស្តាប់បង្គាប់លោកសិន ទោះបីលោកនឹងលើកទ័ពទៅធ្វើការទីណាក៏មិនមានកង្វល់ក្រោយ ឯស្រុកឈីជីវនោះបីដូចជានៅក្នុងកណ្តាប់ដៃលោកៗ នឹងគិតយកពេលណាក៏គង់នឹងបានដោយងាយ ។

(មានត)

# រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

## រឿងព្រេងឥណ្ឌៀ

## លោកសមិន មូត្យុនជម: តែង
## លោកអ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

ព្រះមហាក្សត្រិយ៍ទ្រង់វិចិកិច្ឆាពន់ពេក ទ្រង់ក៏ឡើងទៅលើព្រឹក្សជាតិនោះដោះយកសាកសព ដោយព្រះអង្គឯងរួចព្រះអង្គទ្រង់ចុះមក ។

ក្នុងពេលនោះ, វេតាលៈអគ្គីយល់ថាព្រះមហាក្សត្រិយ៍ មានសេចក្តីវិតក្កជាខ្លាំង ក៏ប្រតិស្ឋានរូបចំពោះព្រះភក្ត្រព្រះអង្គហើយ ក៏និទានរឿងរាវទាំងអស់ថ្លៃប្រាំយ៉ាង ដើម្បីបំបាត់នូវសេចក្តីហត់នឿយរបស់ព្រះអង្គ (រឿងរ៉ាវទាំងថ្លៃប្រាំនោះ មានពណ៌នាដោយពិស្តារនៅក្នុងសៀវភៅវេតាលបញ្ចវីសតិ) ។ រួចតមកវេតាលៈ ក្រាបទូលព្រះមហាក្សត្រិយ៍ថា: "បពិត្រព្រះមហាក្សត្រ សូមទ្រង់ជ្រាបថា យោគីនេះ ជាមេធ្មប់យ៉ាងចំណាន; គាត់នាំព្រះអង្គមកទីនេះ ព្រោះគាត់យល់ថា ព្រះអង្គជាឧត្តមបុគ្គល, ហើយមានសង្ឃឹមថា នឹងយកទ្រង់បូជាយញ្ញ ដើម្បីនឹងឲ្យខ្លួនគាត់បានកើតជាមនុស្សសុវណ្ណ សូមព្រះអង្គកុំប្រមាទត្រូវប្រុងប្រយ័ត្នជាដរាប, បើយោគីនោះមានបង្គាប់ឲ្យព្រះអង្គធ្វើការអ្វីក៏ដោយ ត្រូវព្រះអង្គយល់ថា បើព្រះអង្គឧបត្ថម្ភពួកពាលទុច្ចរិត, កិច្ចទាំងនេះមិនជាការប្រសើរឡើយ" ។

សេចក្ដីថ្លែងនៃវេតាលៈនេះធ្វើឲ្យព្រះពុទ្ធមានវិចិកិច្ឆាជាខ្លាំង ហើយព្រះអង្គទ្រង់ព្រះតំរិះដូច្នេះថា "យោគីនេះ បានលះបង់ភរិយា, បុត្រ, ...ល... ហើយមកធ្វើជាឥសី; អញជាស្ដេចសោយរាជ្យនៅប្រទេសនេះ, ខ្លួនអញជាកដូបត្ថម្ភនៃបុគ្គលម្នាក់ៗ ក្នុងប្រទេសនេះ; អ្នកនេះ មានបំណងចង់យកខ្លួនអញទៅបូជាយញ្ញ ដើម្បីឲ្យខ្លួនប្រែភាពទៅជាមនុស្សសុវណ្ណ ។ ភោគទ្រព្យជាវត្ថុបំណងជាយ៉ាងក្រៃលែងនៃបុគ្គលនេះ; ក្រៅពីភោគទ្រព្យនេះ គាត់យល់ថាគ្មានអ្វីប្រសើរជាង ។ ដើម្បីនឹងឲ្យបានសុខស្រួលចំពោះខ្លួនឯង យោគីកំណាចនេះ មានបំណងនឹងធ្វើឲ្យកើតទុក្ខទោស ជាអនេកប្បការចំពោះជនដទៃឯទៀតជាច្រើន ហើយមិនមានចិត្តរួញរាត្រង់ការប្រព្រឹត្តនូវបាបអកុសលនោះឡើយ ។ ព្រោះហេតុដូចនេះ, បានជាមនុស្សខ្លួត ដោយហេតុមកពីលោភ អាចប្រព្រឹត្តអកុសលដើម្បីប្រាថ្នានូវប្រយោជន៍ផ្សេងៗ ចំពោះខ្លួន, រួចតមក ត្រូវទៅសោយផលទុច្ចរិតនោះ ហើយត្រូវវិលកើតស្លាប់មួយពាន់ជង់ ហើយនឹងវេទនាទុក្ខជាច្រើនយ៉ាង ។ ពួកពាលសាមាន្យ បើទុកជាគេយកទៅជ្រមុជក្នុងមហាសាគរ ដែលមានទឹកបរិសុទ្ធស្អាត ក៏មិនអាចលះបង់នូវអំពើទុច្ចរិតអកុសលនោះឡើយ; ដូចជាពស់ដែលផឹកទឹកដោះនៅសមុទ្រខ្សីរ មិនអាចក្អួតមកវិញនូវទឹកអម្រឹត តែងតែព្រួសសុទ្ធតែពិស ។ តែពិសរបស់សត្វពស់ គេអាចការពារបានដោយសូត្រមន្ត្រ ហើយនឹងឲ្យផឹកនូវឱសថវិសេស ដោយប្រព្រឹត្តទៅតាមគម្ពីរ ដែលសំដែងក្នុងសៀវភៅសីលធម៌ (នីតិសាស្ត្រ) ដូច

ពួកពាលអាចបន្ទរបន្ថយបាននូវអំពើទុច្ចរិត ដែលខ្ញុំប្រព្រឹត្តនេះមានសភាពកាចអស្ចារ្យ; ករណិយកិច្ចនៃព្រះមហាក្សត្រិយ៍ ត្រូវតែពិឃាដមនុស្សមានសភាពបែបនេះ" ។ លុះដល់ព្រះអង្គទ្រង់វិនិច្ឆ័យក្នុងព្រះទ័យស្រេច ព្រះអង្គក៏លើកព្រះខ័នកាប់ក្បាលយោគីនោះភ្លាម ។ស្រាប់តែមនុស្សសុវណ្ណចេញមក សរសើរព្រះតេជានុភាពហើយ ក៏ចូលខ្លួនមកបំរើព្រះអង្គដោយសេចក្ដីគោរពមិនធ្គាំធ្គង តាំងពីពេលនោះមក ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះហសនភាពជាយ៉ាងក្រៃលែង, ទ្រង់កាន់មនុស្សសុវណ្ណនោះ ហើយយាងមកព្រះរាជនិវេសនដ្ឋាន, ដោយអនុគ្រោះនៃមនុស្សសុវណ្ណនោះ ព្រះអង្គសម្បូណ៌ណាដោយភោគទ្រព្យជាងព្រះបាទកុវេរៈទៅទៀត ហើយព្រះអង្គសព្វព្រះរាជហ្ឫទ័យនឹងកាមរាគគ្រប់យ៉ាង ព្រមទាំងដម្រែកផ្សេង ៗ ។

ក្នុងពេលនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះសំទួសេន មកពីប្រទេសកន្យៈកុប្ជៈ ចូលមកក្នុងមន្ទីរក្រុមព្រះរាជប្រឹក្សាព្រះមហាក្សត្រិយ៍ បានថ្វាយបង្គំព្រះអង្គហើយថ្វៃងថា: "បពិត្រព្រះសម្មតិទេព! ជោគវាសនាប្រៀបដូចស្ត្រី បើជោគវាសនាដ៏ឧត្តមរបស់ព្រះអង្គ បានមកពីព្រះអង្គពិតប្រៀបដូចព្រះរាជបុត្រី; បើជោគវាសនាដ៏ឧត្តមនេះ បានមកពីព្រះបរមរាជបិតា ប្រៀបដូចព្រះភគិនី; បើជោគវាសនានេះ បានមកពីអ្នកណាក្រៅពីអ្នកខាងលើនេះ ប្រៀបដូចភរិយាអ្នកដទៃ; សូមព្រះអង្គទ្រង់ពិចារណាឲ្យច្បាស់ថា: និស្ស័យដ៏ឧត្តម មិនដែលចុះសំរុងតាទឹងកាមរាគឡើយ; ព្រោះហេតុដូចនេះ បានជាលោកអ្នកសប្បុរស បើកាលណា

បានផលតាមនិស្ស័យដល់ថ្នាក់ឧត្តមហើយ ប្រឹងបរិច្ចាគទ្រព្យសម្បត្តិទៅជាទាន, ព្រោះអ្នកជាសប្បុរសបុគ្គល ត្រូវតែធ្វើទាន" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់ព្រាហ្មណ៍ហើយ ទ្រង់មានព្រះតំរិះថា: "គង់នៅក្នុងមហាប្រាសាទ, ឡើងគង់លើព្រះរាជទីនាំងអស្សតរដ៏វិសេសនឹងកាជាទ័យដ៏ត្រកាល, ត្រេកត្រអាលសប្បាយនឹងនារីស្អាតផូរផង់, បើទុកជាគ្មានអ្នកណាបានឃើញ ក៏មិនមែនជាលក្ខណៈនៃមហាបុរសទេ ។ អ្នកណាដែលប្រៀបភោគទ្រព្យរបស់ខ្លួនថាមិនមែនរបស់ខ្លួនទៅវិញ អ្នកនោះគឺបានលះបង់នូវអត្តទត្តភាព (égoisme) ហើយមានចិត្តសទ្ធាបរិច្ចាគនូវភោគទ្រព្យនោះទៅជាទានបាន, អ្នកនោះហើយគេទុកជាមហាបុរស អ្នកនោះតែងបានទទួលសេចក្ដីសរសើរ" ។ ព្រះបាទវិក្រមទិត្យកាលទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏តាំងបរិច្ចាគព្រះរាជទ្រព្យទៅជាទាន; នៅគ្រប់ប្រទេស ក្នុងលោកសន្និវាស គ្មានអ្នកក្រទុរ្គតអត់ឃ្លានសោះឡើយ, ព្រះរាជកិត្តិសព្ទក៏ល្បីល្បាញទៅដល់ស្ថានទេវលោក ។

សក្កទេវរាជបានយាងទៅក្នុងទេវសភា បានឮពួកទេវតាពោលសរសើរព្រះរាជកិត្តិគុណនៃព្រះមហាក្សត្រិយ៍វិក្រមទិត្យ ។ ព្រះឥន្ទ្រទ្រង់មានព្រះហឫទ័យសោមនស្សពន់ពេក ហើយទ្រង់មានទេវឱង្ការថា "ក្នុងពិភពលោកនេះ ព្រះមហាក្សត្រិយ៍វិក្រមទិត្យ ជាអភិរាជលើមហាក្សត្រិយ៍ទាំងពួង ដូចជាខ្លួនខ្ញុំដែលជាធំជាងទេវតាទាំងអស់ ។ ព្រោះហេតុនេះ យើងជ្រះថ្លាពន់ពេកចំពោះព្រះមហាក្សត្រិយ៍វិក្រមទិត្យនេះ យើងនឹងធ្វើអំណោយនូវព្រះបល្ល័ង្កទិព្វ ដែលចរនាដ៏វិចិត្រដោយកែវពិទូស្សូរ្យកាន

គ្រប់យ៉ាង ហើយមានរូបគំនូរជារូបទេពនិម្មិត ៣២ រូប ឆ្លាក់ជាក្បាច់សិល្ប ជាប់នៅលើនោះ ៗ ឱព្រះពាយ! ចូរអ្នកយកព្រះបល្ល័ង្កទិព្វនេះជាប្រញាប់ហើយហោះយ៉ាងលឿនតាមនភាល័យ យកទៅដំកល់កណ្ដាលមហាសន្និបាតក្នុងព្រះរាជមន្ទីរ នៃព្រះបរមរាជវាំង ហើយថ្វាយទៅមហារាជវិក្រមាទិត្យ ចំពោះព្រះភ័ក្ត្រ" ៗ អតិរាជវិក្រមាទិត្យទ្រង់បានទទួលព្រះបល្ល័ង្កទិព្វនេះហើយ ទ្រង់ក៏បានបាត់ឲ្យប្រជុំនូវនាហ្មឺនសព្វមុខមន្ត្រី ធ្វើព្រះរាជពិធីរាជាភិសេកគង់នៅលើព្រះរាជបល្ល័ង្កនេះ ៗ កាលណាព្រះអង្គគង់នៅលើព្រះរាជបល្ល័ង្កនោះ ព្រះគេគនកណ្ដាព្រះឥន្ទ្រាធិរាជ គឺវីរភាព (héroisme), ឋាមភាព, ពលភាពនៃសីលធម៌, បរមត្ថបញ្ញា, តេជានុភាព, កម្មិកភាព, ប្រាជ្ញា, វិទ្យា ទាំងប៉ុន្មាននេះទៅជាព្រះរាជចរិយានៃព្រះមហាក្សត្រិយ៍វិក្រមាទិត្យនេះទៅវិញ ៗ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះចិន្ដាថា: "មកអំពីអញបរិច្ចាគទាន ដោយសេចក្ដីណែនាំនៃព្រាហ្មណ៍សិទ្ធសេន បានជាអញបានមកជួបប្រទះនឹងលាភប្រសើរជាយ៉ាងក្រៃលែង គឺព្រះបល្ល័ង្កទិព្វដ៏ថ្លៃថ្លានេះ" ៗ ព្រះអង្គទ្រង់ព្រះដំរិះដូច្នេះហើយ កាលក៏មានព្រះទ័យទន់ទោរទៅរកព្រាហ្មណ៍សិទ្ធសេន ហើយទ្រង់បានតែងតាំងព្រាហ្មណ៍សិទ្ធសេន ជាសមាជិកនៃព្រះរាជក្រុមប្រឹក្សារបស់ព្រះអង្គ ជានាយកលើបណ្ឌិតទាំងអស់ ៗ

ព្រះមហាក្សត្រិយ៍ កាលទ្រង់យាងមកកាន់ទីប្រជុំនៃក្រុមប្រឹក្សាក្នុងព្រះបរមរាជវាំង ក្នុងមួយថ្ងៃ ១ តែងមានមនុស្សទាំងរយនាក់មកបង្គំគាល់ខ្លះចេះខាងគម្ពីរវេទមិមាំសៈ, តក្កៈ, ពួកបណ្ឌិតខាងលទ្ធិសំខ្យ, បតំផលិ,

វាយសេសិកៈ, ពួកសិនិទ្ធៈ ខាងវិទ្យា កល្បវ្យាលណៈ, និរុក្តៈ, ជ្យូតិសៈ, សម្មតិ, ព្រមទាំងពួកវាទកៈ ទីងនាងវាទិកា តែងប្រាណមានវណ្ណស្រស់បំព្រង មានបុរសជាបណ្ឌិតខាងសាស្រ្ត ខាងច្បាប់នយោបាយ ច្បាប់ព្រហ្មទ័ណ្ឌ សៀវភៅវេទ្យវិទ្យា, ...ល... ឯគទគ្គបុគ្គល គឺ កលិទសៈ, វ៉ុសិ កវក្កូទិ, សុបនកៈ; អមរសិម្ហ.; សំកុៈ វេតាលកតៈ, ឃតកប្បរិ, វាហហៈ, ម្ហិរៈ ធំរិតិរៈ ... ល .. ដោយមានពួកបណ្ឌិតជាបរិវារ, ព្រះមហាក្សត្រិយ៍ ក៏បានទ្រង់ព្រះសណ្តាប់នូវកាព្យនិទានផ្សេងៗ ដែលបាននិពន្ធទៅតាមសាស្រ្ត ហើយទ្រង់គង់នៅសោយរាជសម្បត្តិប្រកបដោយសុវត្ថិភាពតទៅ" ។

រូបទេពនិម្មិតទីមួយពោលថា: "ឱអភិរាជរាជ:! ព្រះអង្គឥតមានវិចិកិច្ឆាអ្វីទេឬ? ផែនដីដែលសម្បូណ៌ដោយគ្រឿងអលង្ការគ្រប់យ៉ាងមិនជាការលំបាកនៃអ្នកដែលចង់បាន ដោយប្រើពលកាពនៃច្បាប់ គឺ សមាធិកម្មដ្ឋាន, ធម៌សូត្រ, ទាន, វិទ្យា ។ ពាក្យនិទានអំពីព្រះរាជកិត្តិគុណ ឬព្រះវិទ្ធានុភាពនៃអភិរាជវិក្រមទិត្យ នោះមានជាច្រើនបែបគេមិនអាចនឹងជីងនូវចំនួនបានឡើយ ។ ព្រះជន្មាយុ ១០០ ឆ្នាំ គេមិនអាចបន្ថយចំនួនបាន, តើអវសានជាតិនៃព្រះអង្គមានសភាពយ៉ាងណាទៅ?

ព្រះបាទវិក្រមទិត្យ ដោយទ្រង់បានចាំព្យាករណ៍នៃវេតាលៈអគ្គីថាទ្រង់មានព្រះជន្ម ១០០ ឆ្នាំ, លុះដល់ទ្រង់បានជ្រាបថា ព្រះអង្គជិតដល់ពេលសោយព្រះទិវង្គតហើយ ទើបទ្រង់ព្រះតម្រិះថា "ការណ៍ដែល

ព្រះរាជសម្ភពមកជាវង្សក្សត្រិយ៍ ត្រូវមរណៈក្នុងទីសមរភូមិ ។ ហើយដល់ទ្រង់ព្រះទិវង្គតទៅ មុខជាទ្រង់ទៅបដិសន្ធិទៅស្ថានសួគ៌ ។ កាលព្រះអង្គទ្រង់ព្រះចិន្តាយ៉ាងនេះហើយ ទើបទ្រង់មានព្រះរាជបំណងចង់ធ្វើសង្គ្រាម នឹងមហាក្សត្រិយ៍មួយអង្គ ទ្រង់ព្រះនាមសាលិវាហនៈគង់នៅទីក្រុងប្រតិស្ឋាន ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលសួរសីហនាទ ទៅកាន់ព្រះរាជទីប្រឹក្សាឲ្យរៀបចំកងទ័ពមួយ ។ ព្រះរាជទីប្រឹក្សាទទួលព្រះរាជឱង្ការ ក៏បានប្រមូលព្រះរាជយានមួយពាន់, ព្រះរាជគជេន្ទ្រមួយម៉ឺន ព្រះរាជពាជីមួយម៉ឺន, អូដ្ឋមួយលាន, អស្សតរដប់លាន, ពួកយោធាសរជ័យមួយរយលាននាក់, ពួកកាន់ធ្នូជាច្រើននាក់, គ្រឿងយុទ្ធោបករចេញភ្លើងជាច្រើន, ពួកយោធាកាន់ដាវនឹងពាក់អាវដែកចំនួន ១០០ កោដិនាក់, រំពាត់ដាងមួយរយ, ព្រមទាំងប្រដាប់ដាក់ព្រួញ, ព្រួញ, ធ្នូ, ខែល, ដាវ, លំពែង, បហារណវុធ (គ្រឿងប្រហារ), កាំបិតស្នៀត, ពូថៅ, កាំភ្លើងប្រនេះ, កាំភ្លើងធំនឹងគ្រឿងអាវុធយុទ្ធភណ្ឌឯទៀតជាច្រើន ។ ក្រៅពីនេះ ព្រះរាជទីប្រឹក្សានោះ បានប្រមូលខ្សែ, ដំបង, សំពត់ជ្រំ (តេនត៍) សំពត់ក្រាស់, ព្រះរាជាសនៈ, កួយ, បង្គោល, ទង់ជ័យ, ហើយបានប្រមូល ស្គរធំ, ស្គរជ័យ, ស្គរសុម្ភោ, ស្គរ, ខ្លុយ, ត្រែធំ, ត្រែតូច, ស្នែងផ្លុំសង្គ្រាម, ស្នែងផ្លុំជ័យ, ស្គរតូច, ឆាបនឹងឧស្សរកណ្ឋផ្សេងៗ ។ ព្រះរាជទីប្រឹក្សា បានចាត់ចែងតាមព្រះរាជឱង្ការរួចជាស្រេច ក៏យកសេចក្តីទៅក្រាបបង្គំទូលឲ្យទ្រង់ជ្រាប ។

មហារាជវិក្រមទិត្យ ស្ដេចទ្រង់គង់លើព្រះរាជរថដែលរចនាដាំដោយត្បូងពិទូរ្យនិងកែវផ្សេងៗ ហើយទឹមដោយរាជពាជី ដែលព័ទ្ធជុំវិញព្រះអង្គ មានកងទ័ពញែកជាបួនកងអង្គទ័ព ចោមរោមជាបរិវារ ទ្រង់ចេញចាកព្រះរាជនិវេសនដ្ឋាន ដើម្បីទៅធ្វើសង្គ្រាមនឹងស្ដេចសាលិវាហនៈ ។ ព្រះបាទវិក្រមទិត្យ លុះដល់ស្ដេចយាងទៅដល់រណស្ថាន, ទ្រង់ចូលទៅតស៊ូយ៉ាងសម្បើមអស្ចារ្យ ហើយក្នុងខណៈដែលតទល់នឹងស្ដេចសាលិវាហនៈ ចំពោះព្រះភ័ក្ត្រ ទ្រង់ក៏ចូលកាន់ព្រះទិវង្គតក្នុងពេលនេះ ហើយទ្រង់យាងទៅសោយទិព្វសម្បត្តិឯស្ថានសួគ៌ ។ ប្រទេសអវន្តី ត្រឡប់ទៅជាគ្មានព្រះមហាក្សត្រិយ៍; រាជសម្បត្តិគ្មានអ្នកណាគប់គ្រងតទៅទៀត ។

ព្រះអគ្គមហេសីទីមួយ កាលទ្រង់បានជ្រាបថាព្រះមហារាជវិក្រមទិត្យៈទ្រង់ទិវង្គត ព្រះនាងទ្រង់មានព្រះសវនីយ៍ទៅកាន់ព្រះរាជទីប្រឹក្សា ដោយព្រះវាចាទន់ផ្អែមថា: "លោកកុំបារម្ភអ្វី, ខ្ញុំទ្រង់គភ៌, ខ្ញុំមុខជាប្រសូតព្រះរាជបុត្រមួយព្រះអង្គ ដែលជាព្រះរាជទាយាទសោយរាជ្យស្នងព្រះបាទវិក្រមទិត្យនៅប្រទេសនេះ; ព្រះរាជបុត្រនេះ មុខជាទុកលោកឲ្យធ្វើការនៅទីនេះ តទៅទៀតមិនខាន" ។

(មានត)

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## បរិយាយពីចម្រៀងនិងប្រយោជន៍ចម្រៀង

## របស់លោក ហាប-ពិន

---

តាំងនាមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ខ្ញុំសូមបរិយាយអំពីកំណើតចម្រៀង និងប្រយោជន៍របស់ចម្រៀងដូចតទៅនេះ៖

ប្រស្នា: ការច្រៀងកើតពីត្រឹមណាមក ?

ឆ្លើយ: ការច្រៀងកើតតាំងពីមនុស្សចេះប្រើពាក្យសំដីមក ។

ប្រស្នា: ហេតុម្តេចបានជាប្រជាជនចូលចិត្តច្រៀង? ព្រោះត្រូវការអ្វី ?

ឆ្លើយ: បានជាប្រជាជនចូលចិត្តច្រៀង ព្រោះត្រូវការរស់នៅក្នុងសង្គម, ត្រូវការចិញ្ចឹមបុត្រ, ត្រូវការគូសង្សារ, ត្រូវការអាពាហ៍ពិពាហ៍ ជាដើម ។

ប្រស្នា: ការច្រៀងជាការសំដែងអ្វី ?

ឆ្លើយ: ការច្រៀងជាការសំដែងសាវតារជាតិ-ទឹកចិត្តអធ្យាស្រ័យ និងបំណងរបស់ប្រជាជន គឺថាប្រជាជនមានបំណងយ៉ាងណា ក៏បណ្តាលឲ្យច្រៀងតាមទំនងបំណងនោះ; រួមសេចក្តីថា: ចម្រៀងជាសំឡេងឬជាសម្រែកចិត្តរបស់មនុស្សជាតិពិតៗ ព្រោះបើអ្នកមិនចេះតែងទំនុកខ្លួនឯង ក៏រមែងជ្រើសរើសយកទំនុកចាស់ៗរបស់គេ ដែលអ្នកផងតែងច្រៀងមកច្រៀងតម្រូវតាមសេចក្តីត្រូវការរបស់ខ្លួន ។ មិនតែមនុស្សទេ, សម្បី

តែសត្វស្វាបខ្វះ ដូចសេកសារិកាជាដើម ក៏ធម្មតាបណ្តាលឲ្យគេប្រៀប ជាសម្រែកចិត្តរបស់គេ ចំពោះគូស្នេហ៍របស់គេជាដើមដែរ ព្រោះគេ តែងឃើញគេនៅក្បែរគ្នាជុំមុខមាត់ផ្លៀងផ្លូវផ្ដោះផ្ដងរកគ្នា ដោយសម្លេង ដ៏ពីរោះគ្រលួចគួរឲ្យស្រើះស្រើប ។

ប្រជាជនគ្រប់ជាតិគ្រប់ភាសាគ្រប់ប្រទេស ក្នុងសាកលលោកទាំង សម័យបុរាណ ទាំងសម័យបច្ចុប្បន្ន ទាំងប្រទេសចម្រើនហើយ ទាំង ប្រទេសមិនទាន់ចម្រើន សុទ្ធតែត្រូវការកប់អានការច្រៀងទាំងអស់ សូម្បីទៅសម័យអនាគតក៏ដូចគ្នា ប្រទេសដែលចម្រើនណាស់ គេរិតតែ ត្រូវការណាស់ទៅទៀត ។ ដោយហេតុប្រជាជនក្នុងសាកលលោក ត្រូវការកប់អានចម្រៀងគ្រប់រូប បានជាគេហៅចម្រៀងគ្រប់បែបថា "ចម្រៀងប្រជាមានិត" ឬថា "ចម្រៀងជារបស់ដែលប្រជាជន កប់អាន" ភាសាបារាំងហៅថា (chant populaire) ។

ទំនុកច្រៀងប្រជាមានិត មានសភាពផ្សេងៗគ្នា ប្រព្រឹត្តទៅតាម ស្ថានភាពនៃសញ្ជាតិនៃប្រទេសនិងស័ក្តិរបស់ប្រជាជន ប្រហែលគ្នា នឹងជីវភាពរបស់ប្រជាជាតិក្នុងសាកលលោក ដែលប្លែកៗគ្នាដោយបែបៗ តែរួមចុះក្នុងបទជាសំឡេង ឬសម្រែកចិត្ត របស់ប្រជាជនប្រចាំជាតិ នីមួយៗ ដូចគ្នា ។

ចម្រៀងជាគុណនិងគ្រឿង ជាសិល្បៈមួយផ្នែក ហៅថា "គីតសិល្បៈ" ជាអារ្យធម៌ ឬជាគ្រឹះស្ថានដ៏សំខាន់ប្រចាំសញ្ជាតិ ហើយជា

ជំហររបស់ប្រជាជាតិនីមួយៗ អាចញាំងជាតិឲ្យគង់វង្សដូចភាសា និងអក្សរសាស្ត្រដែលអាចធ្វើជាតិឲ្យឋិតថេរចេរកាលនៅក្នុងលោក ។

តាមពិតភាសាក្តី អក្សរក្តី ចម្រៀងក្តី ភ្លេងក្តីរបស់ជាតិណា ជាគ្រឿងសំគាល់ដ៏សំខាន់សម្រាប់ជាតិនោះ គឺគេគ្រាន់តែឃើញអក្សរ ឮភាសា ចម្រៀងឬភ្លេងរបស់ជាតិណា គេអាចស្គាល់បានភ្លាមថាជាអក្សរ-ភាសា ចម្រៀង-ភ្លេង របស់ជាតិនោះបានជាប្រាកដមិនបាច់ឃើញរូបមនុស្សជាម្ចាស់របស់ឡើយ ។

ចម្រៀងខ្មែរ ជាការ្យធម៌ជាគ្រឹះស្ថានហើយជាគីតសិល្បៈដ៏សំខាន់មួយផ្នែករបស់ខ្មែរ សម្រាប់ឧបត្ថម្ភជាតិខ្មែរឲ្យជាក់ឬសជាប់ឋិតថេរប្រាកដប្រជានៅក្នុងលោក គឺថា ចម្រៀងខ្មែរមាននៅក្នុងលោកដរាបណា ជាតិខ្មែរក៏មាននៅក្នុងលោកដរាបនោះ. បើចម្រៀងខ្មែររលាយសូន្យបាត់ទៅវេលាណា ខ្មែរក៏បាត់ទៅវេលានោះជាប្រាកដ ។ ហេតុនេះខ្មែរយើងគួរសូនគ្រងរក្សាកត់ត្រាទុកនូវចម្រៀងខ្មែរដែលមានបែបបទ និងទំនុកផ្សេងៗ ឲ្យគង់នៅតទៅកុំឲ្យបាត់បង់ ។

តាមពិត ចម្រៀងប្រជាមានិតខ្មែរ មានតាំងពីមានខ្មែរនៅក្នុងលោកនេះមក, ប៉ុន្តែការផ្លាស់ប្តូរសម័យរបស់ប្រទេសខ្មែរ ដូចជាផ្លាស់ពីសម័យ-អង្គរមកជាសម័យភ្នំពេញជាដើម តែងធ្វើចម្រៀងខ្មែរឲ្យផ្លាស់ប្តូរពាក្យពេចន៍ក្នុងទំនុកចាស់ខ្លះ ឲ្យបង្កើតជាទំនុកថ្មីខ្លះ សម្រួលទៅតាមសម័យរបស់ខ្លួនជាធម្មតា ដើម្បីឲ្យប្រជាជនខ្មែរក្នុងសម័យខ្លួនស្តាប់បានងាយ ។

វេលានេះ ខ្ញុំសូមស្រង់យកដោយសង្ខេបតាមដែលចាំបានខ្លះនូវទំនុកច្រៀងចាស់របស់ខ្មែរ ដែលមិនដឹងជាតែងក្នុងសម័យណា និងមិនដឹងជាឈ្មោះណាតែងឬ ក្តីមាច្រៀងមុនៗគេនោះ មកត្រាទុកជាឧទាហរណ៍ក្នុងទីនេះតាមបទនិងទំនុកច្រៀងមានប្រការផ្សេងៗ ដែលជាសំឡេង ឬសារស្រែកចិត្តរបស់ប្រជាជនជាតិខ្មែរសុទ្ធ ដើម្បីរក្សាទុកនូវទំនុកច្រៀងប្រជាប្រិយខ្មែរសម័យបុរាណឲ្យបានឋិតថេរគង់វង្សតទៅ និងដើម្បីជាបទពិចារណាជូនអស់លោកបងប្អូនរួមជាតិពិចារណា ដូចតទៅនេះ ៖

## ទំនុកសំដែងសេចក្តីខ្មាស

ទំនុកច្រៀងមួយបែប ជាសារស្រែកចិត្តរបស់បុរសដែលចង់បានស្ត្រីណាម្នាក់ តែមានគេមកដណ្តើមកាត់មុខយកបានទៅ ក៏បណ្តាលឲ្យច្រៀងសំដែងទឹកចិត្តអៀនខ្មាស មានដើមថា:

ស្រីអើយ! បងបង មានគេដណ្តើមបង
បងមិនចង់នៅស្រុក ស្លាប់ទៅជាខ្មោច
ដេកដីស្រណុក បងមិនចង់នៅស្រុក
ខ្មាសមុខប្អូនស្រី ៗ

## ទំនុកសំដែងសេចក្តីស្តាយ

ទំនុកច្រៀងមួយបែបទៀត ជាសារស្រែកចិត្តរបស់បុរសដែលខ្លួនបានចំណាំស្ត្រីណាម្នាក់ទុកតាំងពីក្មេងមក តែដល់ធំឡើងមានគេមកយកស្ត្រី

នោះគាត់មុខបានទៅ  ក៏បណ្ដាលឲ្យច្រៀងសំដែងទឹកចិត្តសោកស្ដាយ មានដើមថា :

ស្ដាយអើយ  សែនស្ដាយ !  ដូចចេកខ្នួនក្វាយ
ស្រគាលទុំដើម ៗ  បង់ចំស្រោចទឹក  តាំងពីតូចទៅ
ដល់ធំឡើងទៅ  នរណាបេះបាត់ ៗ

## ទំនុកសំដែងសេចក្ដីអាណិត និងសេចក្ដីរ៉ាប់រង

ទំនុកច្រៀងមួយបែប  ជាសម្ដែងចិត្តរបស់បុរសដែលស្រឡាញ់ស្ត្រីណាហើយ ឃើញស្ត្រីនោះធ្វើការនឿយហត់ មានចិត្តអាណិត ក៏បណ្ដាលឲ្យច្រៀងសំដែងសេចក្ដីអាណិត និងសេចក្ដីរ៉ាប់រងមានដើមថា :

ស្រីខ្មៅដើរនួន !  ដាក់មុខស្រីពាន
ខ្មៅបងនឿយណាស់  បើជិតទៅរ៉ា
បងទៅជួយផ្លាស់  ខ្មៅបងនឿយណាស់
ជកជង់ស្លុងជង ៗ

## ទំនុកសំដែងបំណងល្អចំពោះកូន

ទំនុកច្រៀងមួយបែប  ជាសម្ដែងធម៌ៈរបស់ម្ដាយឪពុកដែលចង់ឲ្យកូនស្រីរបស់ខ្លួនបានសម្រេចប្រយោជន៍ល្អ  ក៏បណ្ដាលឲ្យច្រៀងមានដើមថា :

សក្រាក់ទុំផ្កាកំពីងពួយ  កូនស្រីតែមួយ
ទុកឲ្យចិនចៅ  បន្ទាប់ផ្ទះក្បៀង

គ្រឿងឈើស្រឡៅ ទុកឲ្យបិនធៅ

ធ្វើដង្ហៅធំ ៗ

## ទំនុកសំដែងបំណាងបំពោះគូសង្សារ

ទំនុកច្រៀងមួយបែប ជាសារ៉ែមកពន្ធៈរបស់បុរសអ្នកប៉ងចង់បាន ស្ត្រីឯណានីមួយដែលខ្លួនត្រូវចិត្ត ក៏បណ្ដាលឲ្យច្រៀង មានដើមថា:

អាំអើយ ស្រីអាំ! ព្រះពុទ្ធលោកផ្ដាំ

ឲ្យអាំដោយបង បងដាំពោធិ៍មួយ

ពុំទាន់បានធ្លង ឲ្យអាំដោយបង

ធ្លងពោធិ៍ពីរនាក់ ៗ

## ទំនុកសំដែងសំនួររបស់បុរស

ទំនុកច្រៀងមួយបែប ជាសារ៉ែមកពីគំនិតសំដែងសំនួររបស់បុរស អ្នកចង់បានស្ត្រីណាម្នាក់ដែលខ្លួនស្រឡាញ់ ក៏បណ្ដាលឲ្យច្រៀងជាពាក្យដណ្ដឹងស្ត្រីនោះ មានដើមថា:

ស្រីសក្រលុក មុខមាត់ប្រិមប្រិយ

បើបងចូលស្ដី ស្រីព្រមឬទេ?

តាមសង្កេតក្នុងទំនុកច្រៀងសម្រាប់បុរស និងសម្រាប់ស្ត្រីខ្មែរយើង សម័យបុរាណឃើញថែកគ្នា, ខាងបុរសច្រើនប្រើទំនុកសំដែងសេចក្ដីលួងលោមស្ត្រី ដូចស្រង់ទំនុកខ្លះមកពោលហើយក្នុងខាងលើ, ចំណែក

ខាងស្ត្រីវិញ ច្រើនតែប្រើទំនុកសំដែងសេចក្តីបន្ទះបង្អាប់បុរសជាដរាប មានឧទាហរណ៍ ដូចស្រង់មកពោលដោយសង្ខេបតទៅនេះ៖

## ទំនុកសំដែងសេចក្តីបង្អាប់

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់ស្ត្រីដែលដឹងថាបុរសណាត្រូវការនឹងខ្លួន តែខ្លួនមិនត្រូវការនឹងបុរសនោះ ក៏បណ្តាលឲ្យច្រៀងសំដែងសេចក្តីបន្ទះបង្អាប់មានដើមថា :

ប្រុសអើយ ប្រុសព្រាណ! ឃើញស្រីចង់បានមិនមើលមាឱ
គន់មើលទៅមុខដូចកញ្ចប់ជាតុ គន់មើលទៅមារយាទ
ដូចឆ្កែក្រោមផ្ទះ ។

## ទំនុកសំដែងសេចក្តីរិះគន់

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសឬស្ត្រីដែលប្រកបដោយសេចក្តីរិះគន់ មានដើមថា

ក) កញ្ចាញ់ចេកអើយ! លោតទំបុងក្តាត
មេម៉ាយកប់បាត្រ លោកគ្រូចង់សឹក ។
បាសកទៅឃាត់ លោកគ្រូថាទេ
ចង់បានគូគេ ទៅខាងដើងក្តី ។

ខ) លោកគ្រូចង់សឹកប្រញាប់ណាស់
បួសយូរឆ្នាំចាស់ ខានបានប្រពន្ធ ។

គ) ទ្រលុកៗអើយ ! កុំធ្វើបាបលោក
កុំឡោះគរគោក ទុកលោកធ្វើបុណ្យ ។

## ទំនុកសំដែងសេចក្ដីលោភជាការបម្អក

ទំនុកប្រៀនមួយបែប ជាសម្រែកចិត្តរបស់បុរសដែលពោលផ្ដោះផ្ដនទីនស្ដីដោយសេចក្ដីលោភជាការបម្អក មានដើមថា:

ស្រីអើយបនទឹក ស៊ីបាយស្រូបទឹក ប្រាំគោមកន្ទះ
ប្រាំពីរឆ្នាំនដី ប្រាំបីឆ្នាំនខ្ទះ ប្រាំគោមកន្ទះ ស៊ីសោះរមូល ។

## ទំនុកសំដែងសេចក្ដីត្រេកត្រអាល

ទំនុកប្រៀនមួយបែប ជាសម្រែកចិត្តរបស់បុរសដែលពោលផ្ដោះផ្ដនទីនស្ដីដោយតម្រេក មានដើមថា:

ឱម្ចាស់ថ្លៃអើយ! ដែលបងគន្ធុយ បងអត់ននុយ
ចាំស្រីរ៉ៃ, រវៃរួចហើយ បំពេញសណ្ដាន់ ខ្មៅខែត្រន់
នាំអូនចូលគេង ។

## ទំនុកសំដែងសេចក្ដីសរសើរ

ទំនុកប្រៀនមួយបែប ជាទំនុកសំដែងសេចក្ដីសរសើរនៃប្រៀបធៀប ឲ្យអ្នកស្ដាប់កើតគំនិតគិតដល់ឋានៈពាបខ្លួនរបស់ខ្លួន ថាមិនមែនមានតែខ្លួនម្នាក់ឯងគ្រាន់បើជាងគេទេ មានគេឯទៀតគ្រាន់បើដែរ មានដើមថា:

អញថាកុំស្រួច ស្រួចអីតែឯង
មានកុំកម្រែន រែនហើយស្រួចផង ។

## ទំនុកសំដែងបំណងនឹងជំនឿ

ទំនុកច្រៀងមួយបែប ជាទំនុកសំដែងបំណងនឹងជំនឿក្នុងអំណោយទាន មានដើមថា:

៙ សត្វមហោរី យំស៊ីផ្លែជ្រៃ ធ្វើបុណ្យទានអ្វី
ឲ្យកើតផ្លែទៀត កើតផ្លែពីមុន ផ្លែហាលបង់សៀត
ឲ្យកើតផ្លែទៀត ជាក់ទានសព្វសត្វ ។ល។

ទាំងបទទាំងទំនុកចម្រៀងមហោរី គួរចាត់ទុកជាចម្រៀងថ្នាក់ខ្ពស់មួយបែបរបស់ខ្មែរឥតទរណាកែប្រែបាន ដែលតាមភាសាបារាំងហៅថា ចម្រៀងក្លាស៊ិករបស់ខ្មែរ ។

*

* *

## ទំនុកច្រៀងនៅពេលធ្វើមង្គលការ

បណ្ដាចម្រៀងប្រជាមានិតខ្មែរទាំងអស់ ចម្រៀងដែលមានទំនុកច្រើនជាងគេ គឺចម្រៀងក្នុងមង្គលការ, បន្ទាប់មកចម្រៀងលៀងអារក្សនឹងឡើងអ្នកតា; ចម្រៀងក្រៅពីនេះមានទំនុកបន្ទាប់បន្សំ ។

របៀបការៈមង្គលការដែលមានច្រើនថ្នាក់ គឺថ្នាក់ចូលរោងកាត់សក់, ឡើងអ្នកតា, លើកជំនួន, រៀនផ្លែឈើ, ក្រុងពាលី, សំពះរោង, ចំរើនបរិត្ត, កាំខ្វែរបុកល័ក្ត, ធ្វើធ្មេញ, ដោតផ្កាស្លា, សំពះកនពេលា, ហូតផ្កាស្លា, សុំកូនចេញផ្ទឹម, បើកបាយខុន (ឲ្យពារចងដៃ) គោងស្បៃចូលក្នុង, សាកន្ទួល (ក្រោយផ្ទឹមរួច) រៀបស្លាកលើកស្លក សំពះ

អាចារ្យមហា ទឹងផ្សំដំណេក (បញ្ចុកបេកនំ) សុទ្ធតែត្រូវប្រើនគ្រប់ថ្នាក់ទាំងអស់ ហើយមានទំនុកទឹងបទជាច្រើនសម្រាប់ប្រើងក្នុងថ្នាក់ទាំងនោះ តាមលំដាប់ គឺបទសារពេមេ, ហុំរោង, សំពោង, ផាត់ជាយ អង្គរាជស្តេចផ្ទំ, លោមនាង, ថ្មមនាង, ព្រថោង, នាងខាត, នាគព័ន្ធ, កន្ទ្រែគប្ដូរែត្រ, កន្ទង់រ័ត្ន, កាត់ត្រើយ, សារាយអណ្តែត, កន្សែងក្រហម, កន្សែងស្បូត្រ, ដំរីស, ក្អែងបុកក្អែងបណ្តែត, រៀងផ្លែឈើ, បំពេរ អុំទូក, កាត់សក់, បុកល័ក្ត, ដោតផ្កាស្វាប្ដូរផ្កាស្វា, សំពះពេលា, បើកបាយខ្ញុំ, សាកន្ទេល, ត្រាំងដោះក្រាល, ស្តេចដើរ, លលេរ, មួយដួង, អន្ទក់ពាំង, ចន្ទា, សំពៅថយ ទឹងកងសោយ ។

បម្រើងក្នុងមង្គលការដែលមានច្រើនទំនុកប្រែបទដូចពោលមកនេះ តាមសង្កេតសព្វគ្រប់ទៅឃើញទំនុកខ្លះ ជាទំនុកសំដែងសេចក្ដីសប្បាយ, ខ្លះសំដែងសេចក្ដីគោរព, ខ្លះសំដែងសេចក្ដីទូន្មាន ។ល។ ហើយខ្លះមានប្រយោជន៍ច្រើន ខ្លះមានប្រយោជន៍តិច ដែលមិនអាចស្រង់យកមកពោលឲ្យសព្វគ្រប់ក្នុងទីនេះបានព្រោះពេលខ្លី ប៉ុន្តែទោះបីមានច្រើនបែបដូច្នេះ ក៏រួមចុះក្នុងសេចក្ដីសំដែងសរសើរមកចិត្តរបស់ជនជាមេបាគ្រួសារដែលប្រាថ្នាឲ្យសាមីខ្លួនកូនទៅជាអ្នកការថ្មី បានសេចក្ដីសុខសេចក្ដីចម្រើនទាំងអស់ ។

សូមស្រង់ទំនុកខ្លះក្នុងបណ្ដាទំនុកប្រើងមង្គលការ មកពោលក្នុងទីនេះដោយសង្ខេប ដូចតទៅនេះ ៖

# ទំនុកហុំរោងឬបើករោង

ទំនុកប្រៀនមួយបែបជាទំនុកសំដែងសេចក្តីគោរព សេចក្តីសូមពរ ចំពោះវត្ថុស័ក្តិសិទ្ធិទៅពេលចូលរោងការ ហៅថា "ទំនុកហុំរោងឬបើករោង" មានដើមថា:

យើងខ្ញុំសុំនមស្ការ លើកហត្ថលើសិរសី
បង្គំកែវទាំងបី សូមសេរីជ័យជំនះ ។
ហើយលេងភ្លេងហុំរោង តាមទំនងទំនៀមចាស់
ភ្លេងផ្តើមជាដើមអាសន៍ បើកប្រកាសដាស់ទេវតា ។
ថ្ងៃនេះថ្ងៃជោគជ័យ ញាតិប្រុសស្រីក្មុំមេបា
ទីនេះរៀបមង្គលការ លៀងអាហារពិសាហត្ថ ។
ហេតុនេះសូមទេវតា តៅអ្នកតាបាចាស់ស្រុក
ការពារឲ្យបានសុខ ចាកក្តីទុក្ខភ័យទាំងឡាយ ។
អញ្ជើញព្រាយកុមារ ព្រែបត្តាទីជិតឆ្ងាយ
ចូលមកយកស្រាបាយ ហើយប្រែកាយឲ្យពរជ័យ ។
ដល់លោកអ្នកទាំងឡាយ សុខសប្បាយទាំងប្រុសស្រី
ព្រមទាំងគូស្វាមី ទើបការថ្កុំបីហ្ន ។
ហុំរោងប្រាំពីរបទ ចប់កំណត់ត្រឹមនេះហោង
សូមឲ្យអស់ញាតិផង ជួយគិតគន់ហោយកជ័យ ។
ជ័យហោងហៅជយោ យើងស្រែកហៅគំរប់បី
កម្រើកបើករោងថ្មី ជោគសួស្តីហោយជាក់ច្បាស់ ។

# ទំនុកបើកបាយខន

មានទំនុកប្រៀនមួយបែប ជាទំនុកសំដែងសេចក្ដីគោរពចំពោះត្រកូលរៀមច្បងសូមកូនស្រីមកផ្ដឹម សម្រាប់ប្រៀនកូនមង្គលការនៅពេលមុនផ្ដឹម គឺពេលដែលកូនប្រុសមកអង្គុយលើអាសនៈកណ្ដាលហុងមេបាប្រុងចាំកូនស្រីមកផ្ដឹម មានដើមថា:

បាយខុនបងដៃ អំបោះ១សរសៃ ថ្ងៃស៊ើទីងមាស
ទឹកដូលសម្រិទ្ធ ប្រសិទ្ធនុភាស លើកឡើងគ្រកស
ត្រដួបគួបហត្ថ ។

ថ្ងៃនេះជាថ្ងៃជា ថ្ងៃបានពេលា យកពារយាមសត្វ
ពេលសំពួអក្សរ អរុណសុវត្ថិ ពារពពកផាត់ ពន្លឺពេញវង់ ។

ព្រួសបូរគងហើយ អ្នកក្រាបលើខ្នើយ
ប្រងលុតជួញជង់ ដៃចាប់ស្លាពារ
លើកទ្រទម្រង់ ហត្ថាព័តវង់
ហូតដាក់ចំជង ។

ច្បងជូនឪពុក ហើយទើបក្រាបទុក
ជូនទៅមាយផង ទោជូនមាស្រី
ទីបីជូនបង រៀបតាមរៀមច្បង
ទំនៀមបុរាណ ។

ស្លាពារទាំងបី ជូនមេបាស្រី
ជាស្រេចគ្រប់ប្រាណ កូនប្រុសគោរព

គ្រប់ញាតិសន្តាន ចាំស្រីកល្យាណ
ចេញប្រាណមកផ្ទឹម ។
អនអើយ ! ស្រីអន ! សុំបើកវាំងនន
ឱ្យអនអមទឹម ដឹកដៃកូនស្រី
ប្រឹមប្រិយញញឹម ក្រាបម៉បអបផ្ទឹម
នៃបទឹមលោកប្រុស ។

## ទំនុកបើកវាំងនន

អនអើយ ! ស្រីអន ! សុំបើកវាំងនន
សុំអនមកផ្ទឹម ជ្រិតពេលថ្ងៃនេះ
ទាន់នៅព្រលឹម សុំអនមកផ្ទឹម
គូព្រេងដល់ហើយ ។

## ទំនុកបំពេរ

ទំនុកច្រៀងមួយបែប ជាទំនុកសំដែងដំបូន្មាន ដែលម្តាយទូន្មានកូនស្រី សម្រាប់ច្រៀងក្នុងមង្គលការនៅពេលចងដៃ ហៅថា "ទុកបំពេរ" មានដើមថា:

កូនអើយ ! ចាំស្តាប់ ម្តាយច្រៀងបំពេរ ពាក្យឯកថ្លៃកេរ
ជាមេច្បាប់ចាស់ ចូរចាំជាក្រិត្យ ព្រោះជ្រិតក្រណាស់ ធម៌តា
មេផ្ទះ ប្រុះគេចំណេញគិត ។
កើតមកជាមនុស្ស ទើសនៅគំនិត

ត្រូវរៀនរិះគិត　　មើលចិត្តស្វាមី ។
កុំដើរបង់សៀត　　ឃាតផ្លូវរាត្រី
បើមានការអ្វី　　ប្រាប់ប្ដីឲ្យដឹង ។
ចូលគេងកូនឯង　　កុំថ្ងូររៀងរឹង
កុំត្អូញត្អែរ　　ក្រញាំងក្រញូវ
យប់យន់យូរហើយ　　នាងអើយ ! គេងទៅ
ព្រោះពេលយប់ជ្រៅ　　ប្ដីទៅបំពោរ ។
នាងនឿយពីថ្ងៃ　　គ្មានដៃទំនេរ
បម្រើរត់រេ　　ដោយគេការពើង ។
នាងគេងកាលណា　　កុំផ្ទាប់ដៃឡើង
មួយទៀតកុំទើង　　គេងទឹមក្បាលប្ដី ។
បើជួនជាពាល់　　កាន់ដល់កេសី
ត្រូវមានសំដី　　សុំទោសតាមការ ។

*
*　*

បម្រៀនប្រជាមាតិខ្មែរយើង មានច្រើនទំនុកច្រើនបទជាអនេក លើសគណនា ពុំអាចពណ៌នាឲ្យចប់សព្វគ្រប់កន្លែងនេះបាន; ប៉ុន្តែ ទោះជាច្រើនដូច្នោះ ក៏សង្កេតសព្វគ្រប់ទៅឃើញថា បម្រៀនប្រជា-មាតិខ្មែរទាំងប៉ុន្មាន ទោះជាយ៉ាងណា ក៏សុទ្ធតែទុកជាសរសៃមកចិត្ត របស់ប្រជាជនខ្មែរជាតិទាំងអស់ ហើយជារបស់មានប្រយោជន៍ដោយ

យ៉ាងទៅតាមទំនុកតាមបទ, ប្លែកខ្លះ តិចខ្លះច្រើន, ដែលស្រង់ទំនុកខ្លះមកពោលខាងដើមនេះ សង្ខេបណាស់គ្រាន់តែជាឧទាហរណ៍ ទីងជាបទពិចារណាជូនបងប្អូនរួមជាតិពិចារណាប៉ុណ្ណោះ; សូមបញ្ចប់ត្រឹមប៉ុណ្ណោះ ។

## និគមវចនៈ

ចម្រៀងខ្មែរបាត់, ជាតិខ្មែរបង់ មិនឋិតនៅគង់យូរប៉ុន្មាន
ចម្រៀងខ្មែររស់, ខ្មែររស់បាន ជនខ្មែរគួរមានកត្តិភាព ។
ក្រោយចម្រៀងខ្មែរឲ្យនៅ ចម្រើនតទៅជារៀងរាប
ឲ្យរិតតែខ្ពស់កុំឲ្យទាប កុំសាបរលាបដល់អវសាន ។

បាប - ពិន

## កំណត់និងប្រវត្តិការណ៍

# អនុសំវច្ឆរមហាសន្និបាតទី ១១ នៃមន្ត្រីសង្ឃ

# សម្រាប់ឆ្នាំ ១៩៥៥

---

កាលពីថ្ងៃទី ៨ និងទី ៩ ខែមករា ឆ្នាំ ១៩៥៥ មន្ត្រីសង្ឃទាំងឡាយក្នុងទីក្រុងនិងខេត្តក្រៅ នៃព្រះរាជអាណាចក្រកម្ពុជា បានធ្វើការប្រជុំអនុសំវច្ឆរមហាសន្និបាតទី ១១ នៅវត្តបទុមវតី, វត្តឧណ្ណាលោម និងវត្តព្រះកែវមរកត ។

## សន្និបាតនៅវត្តបទុមវតី

ថ្ងៃសៅរ៍ទី ៨ មករា ពេលម៉ោង ១៥, ៣០ នៅក្នុងព្រះវិហារវត្តបទុមវតី មានការជួបជុំមន្ត្រីសង្ឃនិងចៅអធិការ ខាងគណៈធម្មយុត្តិក្នុងព្រះរាជធានី ដែលមានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក ព្រះព្រហ្មមុនី អ៊ូ ជាចាងហ្វាងវេសាលាបាលីជាន់ខ្ពស់ និងព្រះអរិយកស្សប អ៊ុច ជាដើម ដោយមានឧបាសក ឧបាសិកាជាច្រើននាក់អញ្ជើញមកជួបជុំផង ។ ការសន្និបាតនៅវត្តនេះ ធ្វើឡើងក្រោមអធិបតីភាពនៃឯកឧត្តម ប៉ាល់ ជួន រដ្ឋលេខាធិការក្រសួងធម្មការ និងសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក ។

កាលមន្ត្រីសង្ឃនិមន្តមកជួបជុំហើយ ឯកឧត្តម ប៉ាល់ ជួន ដែលមានលោកឈុន-យឿន នាយកការិយាល័យអមផង ក៏បានអញ្ជើញ

មកដល់ហើយចូលទៅថ្វាយបង្គំព្រះសង្ឃខាងក្នុងព្រះវិហារ ។ រួចហើយ ឯកឧត្តមបានសន្ទនាជាមួយនឹងមន្ត្រីសង្ឃ ខាងផ្នែកសាសន សិក្សាដែលប្រទេសយើងក្នុងសម័យនេះ កំពុងត្រូវការអ្នកចេះដឹងគ្រប់ផ្នែកទាំងផ្លូវលោក ទាំងផ្លូវធម៌ ដើម្បីនាំទ្រទ្រង់ឲ្យសមតាមកិត្តិយស ។ ការប្រស្រ័យរាក់ទាក់ឯកឧត្តម ប៉ាល់-ជួន នឹងមន្ត្រីសង្ឃ នៅវត្តបទុមវតីនេះ អស់ពេល ២៥ នាទី ។ បន្ទាប់ពីនោះមក ឯកឧត្តមអញ្ជើញទៅវត្តឧណ្ណាលោម ។

## សន្និបាតនៅវត្តឧណ្ណាលោម

នៅថ្ងៃដដែល វេលាម៉ោង ១៦ មន្ត្រីសង្ឃគណៈមហានិកាយមានសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក, សម្ដេចព្រះធម្មលិខិតឧត្តម-ប្រិក្សាវត្តលង្កា, ព្រះពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ និងរាជាគណៈ ឋានានុក្រម ក្នុងទីក្រុង ព្រមទាំងមេគណ, អនុគណ ចៅអធិការជាដើមក្នុងព្រះរាជាណាចក្រទាំងមូល បាននិមន្តទៅជួបជុំនៅជាន់ខាងក្រោមនៃមហាកុដិ ។ ការសន្និបាតនេះ ធ្វើឡើងក្រោមអធិបតីភាពនៃឯកឧត្តម ប៉ាល់-ជួន រដ្ឋលេខាធិការក្រសួងធម្មការ និងសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក ។

ឯកឧត្តម ប៉ាល់-ជួន កាលអញ្ជើញចេញពីវត្តបទុមវតី ចូលទៅកាន់ទីសន្និបាតសង្ឃវត្តឧណ្ណាលោមហើយ ក៏ថ្វាយបង្គំសម្ដេច និងព្រះសង្ឃ រួចមានប្រសាសន៍ប្រស្រ័យចំពោះព្រះថេរានុត្ថេរជាកិច្ចបដិសណ្ឋារ, បន្ទាប់មក ក៏ចាប់ផ្ដើមបើកឱកាសប្រជុំ ដោយថ្លែងទទួល

អំណររចំពោះការទទួលមកនៃព្រះសង្ឃគ្រប់អង្គ ក្នុងព្រះរាជអាណាចក្រ ដែលនាំយកព្រះទ័យទុកដាក់ដល់ទីប្រជុំ ដើម្បីរិះរកមធ្យោបាយ ឲ្យកើតមានវិវឌ្ឍន៍ក្នុងផ្នែកសិក្សា ចំពោះព្រះពុទ្ធសាសនា ។

បន្ទាប់ពីឯកឧត្តមមក, សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក បានមានថេរដីកាពន្យល់ដល់ទីប្រជុំអស់ពេលយ៉ាងយូរ អំពីពាក្យពេចន៍ខ្លះដែលមេគណ, អនុគណ បានផ្ញើមកដោយស្នើយ៉ាងយ៉ាត ពុំត្រូវតាមរាជសព្ទ តាមដើមកំណើតសព្ទ អំពីកិច្ចសិក្សាខាងធម្មវិន័យ; នៅទីបំផុត សម្តេចបានរិះរកមធ្យោបាយ ឲ្យបានស្រួលដល់សិស្សសមណៈ ដែលប្រឡងប្រជែងខាងធម្មវិន័យ ។ មុននឹងបញ្ចប់ សម្តេចបានមានថេរដីកាសុំឲ្យព្រះសង្ឃដែលទទួលមកពីគ្រប់វត្តក្នុងព្រះរាជធានី និងគ្រប់ខេត្ត រួមព្រះទ័យជាមួយនឹងលោកឧទ្ទិសព្រះរាជកុសលថ្វាយចំពោះព្រះប្រិយមហាក្សត្រ ដោយស្វាធ្យាយធម៌ ប្រសិទ្ធិពរថ្វាយជោគជ័យជាដើម ។ ការប្រជុំអនុសំវច្ឆរសន្និបាត នៅវត្តឧណ្ណាលោម បានបញ្ចប់នៅម៉ោង ១៨ គឺម៉ោង ៦ រសៀល ។

## មហាសន្និបាតនៅវត្តព្រះកែវមរកត

នៅថ្ងៃកាទិត្យទី ៩ មករា ឆ្នាំ ១៩៥៥ មន្ត្រីសង្ឃ និងចៅអធិការព្រមទាំងភិក្ខុសាមណេរ ទាំងក្នុងក្រុង ទាំងខេត្តក្រៅ ទាំងគណៈធម្មយុត្តិ ទាំងគណៈមហានិកាយ បានប្រជុំមួយលើកទៀត ជាប្រជុំធំនៅវត្តព្រះកែវមរកត ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណា ជាអម្ចាស់ជីវិតលើ

ត្បូង ។ មុនពេលដែលព្រះមហាវីរក្សត្រស្តេចយាងដល់, ព្រះសង្ឃទាំងពីរគណៈ បានចំរើនសត្តប្បករណ៍ ឧទ្ទិសថ្វាយព្រះរាជកុសលចំពោះព្រះបិតា គឺខ្ទុតក្តជាដែលសោយព្រះទីវង្គតហើយ ដែលដំកល់ព្រះអដ្ឋិធាតុទុកនៅព្រះចេតិយក្នុងវត្តព្រះកែវមរកត ។

នៅម៉ោង ៩ និង ១៥ នាទី សមាជិកព្រះរាជរដ្ឋាភិបាល ដែលមានឯកឧត្តម ប៉ែន-នុត ជានាយក, ឯកឧត្តម យិត-ស្រេន ប្រធានក្រុមប្រឹក្សាជាតិ, សមាជិកក្រុមប្រឹក្សាជាតិ ឯកឧត្តមញឹក-នូវ ចាងហ្វាងពិធីការក្នុងព្រះបរមរាជវាំង និងមន្ត្រីក្រសួងធម្មការ សុទ្ធសឹងស្លៀកពាក់សំពត់តាមប្រពៃណីជាតិ បានអញ្ជើញទៅឈរតំរៀបជាជួរនៅមាត់ទ្វារព្រះកែវមរកតរង់ចាំថ្វាយបង្គំទទួលព្រះមហាវីរក្សត្រ ។

ម៉ោង ៩ និង ៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានស្តេចយាងដោយព្រះទីនាំងរថយន្ត ដល់មាត់ទ្វារព្រះកែវមរកត ដោយមានឯកឧត្តម អ៊ុំ-ឈាង-ស៊ុន ក្រុមប្រឹក្សាឯកជនអមព្រះអង្គ, លោក ឌី សាត លេខាធិការផ្ទាល់ព្រះអង្គ និងលោកវរសេនីយត្រី មាស-ហ៊ុល នាយទាហានបង្គាប់ការផ្ទាល់ព្រះអង្គ បានអញ្ជើញហែហម ។ ក្នុងខណៈនោះ គណៈរដ្ឋមន្ត្រីក៏បានថ្វាយបង្គំ ហើយដង្ហែព្រះអង្គជាមួយនឹងក្រុមគ្រួសារបន្តមកទៀត ។ ក្រោយដែលក្រុមភ្លេង និងក្រុមទាហានគោរពព្រះអង្គ ប្រគំបទភ្លេងនគររាជធ្វើការគោរពរួចហើយ, ព្រះរាជាបានស្តេចយាងចូលទៅក្នុងមន្ទីរព្រះសទ្ធម្ម ដោយដោះទ្រនាប់ព្រះបាទ គង់ប្រថាប់ផ្ទាល់កម្រាលព្រះរាជាសនៈ ហើយព្រះមហាក្សត្រថ្វាយបង្គំព្រះសង្ឃ

ដែលមានសម្តេចតាំងពីព្រះអគ្គជាប្រធាន ៗ ដើម្បីជាកិច្ចប្រស្រ័យចំពោះព្រះសង្ឃ ដែលបាននិមន្តមកប្រជុំអនុសំវច្ឆរមហាសន្និបាតទី ១១ នេះ ព្រះនរបតីបានទ្រង់ព្រះរាជនុញ្ញាតទូលព្រះបន្ទូលសួរសីហនាទ យ៉ាងវែង ហើយយ៉ាងជាក់ច្បាស់ទៅកាន់ព្រះសង្ឃទាំងត្រៃហស្ស នូវស្ថានការណ៍ក្នុងប្រទេសនិងក្រៅប្រទេស ៗ ក្នុងទីបំផុត ព្រះមហាវីរក្សត្របានមានព្រះរាជនុញ្ញាតទទួលបញ្ជាក់ថា អនាគតនៃប្រទេសយើងមានស្ថានភាពគួរឲ្យព្រួយបារម្ភ កាលបើអ្នកនយោបាយបេះតែខ្សឹបខ្សៀវឃោសនាបំភាន់រាស្ត្រឲ្យយល់ឃ្លាងពីស្ថានការណ៍ពិត ៗ ព្រះរាជនុញ្ញាតទូលព្រះបន្ទូលសួរសីហនាទយ៉ាងវែងនេះ បានបញ្ចប់នៅម៉ោង ១១ និង ២១ នាទី ព្រះសង្ឃបានស្វាធ្យាយទិព្វមន្តជយន្តោ ប្រសិទ្ធិពរជ័យ ចំពោះព្រះភូមិន្ទជាទីបញ្ចប់កិច្ច ៗ ព្រះរាជាបានស្តេចយាងត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដោយមានឥស្សរជនដែលដង្ហែអមព្រះអង្គផង ៗ

មន្ត្រីសង្ឃដែលនិមន្តមកប្រជុំអនុសំវច្ឆរៈមហាសន្និបាតនេះ បានទៅទទួលភត្តាហារថ្ងៃត្រង់នៅក្នុងមហាកុដិវត្តឧណ្ណាលោម ក្នុងព្រះបរមនាមនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងក្នុងនាមនៃឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការ ៗ

ពុទ្ធសាសនបណ្ឌិត្យ

---

# ពិធីបុណ្យទក្ខិណានុប្បទាន

## របស់ព្រះសាសនមុនី មាស - កង់ ចៅអធិការវត្តពិភទ្ធរង្សី

## ព្រះវិនយធរអនុគណ ឯក - ញិម

### រៀបរៀង

---

កាលពីថ្ងៃសៅរ៍ · អាទិត្យ ១២ - ១៣ កើតខែអស្សុជ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃ ១០ - ១១ ខែតុលា ឆ្នាំ ១៩៥៤

ព្រះសាសនមុនី មាស-កង់ ជាគណៈជាន់ទោ ចៅអធិការវត្តពិភទ្ធរង្សី សង្កាត់លេខ ២ ក្រុងភ្នំពេញ បានធ្វើបុណ្យទក្ខិណានុប្បទានជាឧឡារិកក្នុងវត្តពិភទ្ធរង្សី ដើម្បីឧទ្ទិសផលប្រគេន - ជូនចំពោះគ្រូឧបជ្ឈាយាចារ្យ នឹងមាតាបិតា របស់លោក ដែលទទួលអនិច្ចធម្ម-អនិច្ចកម្មទៅយូរឆ្នាំហើយ ៗ .

លើកទី ១ ថ្ងៃសៅរ៍ ១២ កើតឆ្នាំមមី ពេលព្រឹកមានរៀបពិធីតាំងគ្រឿងសក្ការៈដោតទង់ជ័យដាក់ផ្កាថ្វាយព្រះរតនត្រ័យ ដើម្បីអភិសេកព្រះពុទ្ធរូបថ្មពណ៌សទ្រង់ឈរបិណ្ឌបាត ២ ព្រះអង្គដែលទើបនឹងសាងថ្មី ព្រមទាំងរៀបគ្រឿងផ្កាពណ៌ផ្សេងៗ មានផ្កាចំប៉ាជាដើម ធ្វើជាស៊ុំបង់ព័ទ្ធជុំវិញ ៗ ឆាយារូបទាំង ៤ គឺរូបព្រះសពព្រះពោធិវង្ស ទេព ១ រូបព្រះសពញិក ១ រូបព្រះសម្អាងសារពេជ្រ ហាស់ - មាស ១ រូបឧបាសិកាសួរ - យ៉ុន ១ ដែលដាក់កញ្ចក់ដម្កល់ទុកនៅពីខាងឆ្វេង នឹងពីខាងស្តាំអមពុទ្ធាសនៈ នៅក្នុងឧបដ្ឋានសាលាធ្វើបុណ្យ បើឃើញគួរឲ្យជ្រះថ្លា ៗ ការគ្រឿងផ្កានេះជាស្នាដៃយាយ ៗ នៅរៀនធម៌ជួយឧបត្ថម្ភ ៗ

លុះដល់ម៉ោង ២០ ពួកឧបាសក ឧបាសិកា ជួបជុំនមស្ការ១ រូប ហើយព្រះវិន័យធរអនុគណ ឯក ញឹម ចៅអធិការវត្តធម្មិស្សរារាម ខែត្រសៀមរាប ក្រោកឈរឡើងថ្លែងសុន្ទរកថា តាងនាមព្រះសាសនមុនីមហាថេរជាដើមបុណ្យ, ក្នុងផ្ទៃនៃសុន្ទរកថានោះ មានរៀបរាប់ប្រវត្តិត្រៃបុគ្គល ទាំងឧទ្ទិសផលជូនទៅបុព្វការីនៃលោកទាំងថ្វាយព្រះរាជកុសលចំពោះព្រះករុណាព្រមទាំងព្រះរាជវង្សានុវង្ស ទាំងជូនគាត់ឧត្តមផលដល់លោកអ្នករាជការគ្រប់ក្រសួងគ្រប់ដំណែង ព្រមទាំងសហការីជាភ្នាក់ងារនៃរាជការនោះៗ លុះចប់ហើយក៏ឡើងថ្លែងទេសនារំលឹកស្មារតីលោកអ្នកមកជួយធ្វើបុណ្យទាំងកតញ្ញូកតវេទិតាធម៌ ចំនួន ១ ម៉ោង ។ លុះដល់ម៉ោង ២២ និមន្តព្រះបាឡាត់ គិម វត្តមហាមន្ទ្រី ភ្នំពេញ ទេសនាតទៅទៀតចំនួន ១ ម៉ោង ។ ហើយឈប់សម្រាកម្តងក្នុងរាត្រីនោះ លុះដល់ម៉ោង ៥-៣០ និមន្តព្រះមហាថេរដែលមកពីវត្តក្រៅក្រុង ២០ អង្គ សូត្រថ្វាយពុទ្ធជយមង្គល ដល់ព្រះពុទ្ធរូបដែលសាងថ្មីនោះ ។

## សុន្ទរកថា

សូមថ្វាយបង្គំ ចំពោះសម្តេច ដោយគោរព,
សូមថ្វាយបង្គំ ដល់ព្រះថេរានុត្ថេរៈទាំងឡាយ,
សូមជំរាប ឯកឧត្តម ព្រះតេជព្រះគុណនិងលោកអ្នកទាំងឡាយ !
សូមទានជ្រាប, សូមជ្រាប ។

ខ្ញុំព្រះករុណា អាត្មាភាព សូមឱកាសថ្លែងសុន្ទរកថា តាងនាមព្រះតេជព្រះគុណព្រះសាសនមុនី និងជាដំណាងនាមពុទ្ធបរិស័ទទាំងឡាយ

ជាចំណុះវត្តពិកទ្ធេរង្សីនេះដែលធ្វើបុណ្យឧទ្ទិសផលដល់តែបុគ្គល, ហេតុនេះ សូមសំគាល់ពាក់តាតទៅ ថាជាពាក់តារបស់លោកថ្ងៃនេះដោយព្រះអង្គឯង ៗ

សម្តេច - ឯកឧត្តម - អស់លោកអ្នកទាំងឡាយ !

បុណ្យនេះជាបុណ្យរំលឹកឧបការគុណមាតា-បិតា គ្រូឧបជ្ឈាយាចារ្យផង, ជាបុណ្យចំរើនអាយុសង្ខាររបស់ខ្ញុំដែលកន្លងទៅហើយបាន ៦៣ ឆ្នាំ ទីឆ្នាំនេះផង ទើបធ្វើឲ្យមានចីវរទាន, បិណ្ឌបាតទាន, សេនាសនទាន, ភេសជ្ជទាន, ជាអាមិសទាន និង ធម្មទាន ដោយធនធានរបស់ខ្ញុំខ្លះ, ដោយសេចក្តីឧបត្ថម្ភរបស់សិស្សានុសិស្ស និងលោកអ្នកដែលជាឧបាសក ឧបាសិកា ព្រមទាំងកល្យាណមិត្តទាំងឡាយខ្លះ, ដែលបានជួញចិត្តចូលខ្លួនមកជួយឧបត្ថម្ភដោយកម្លាំងកាយ និងធនធាន, ខ្ញុំព្រះករុណា អាត្មាភាព មានមនោសព្វេតនាសោមនស្សត្រេកអររីករាយដ៏ក្រៃលែងក្នុងដំណើរសម្តេច, ព្រះករុណា គ្រប់អង្គ ឯកឧត្តមនិងអស់លោកទាំងឡាយដែលបាននិមន្តនិងអញ្ជើញមកជាកិត្តិយសដ៏ប្រសើរក្នុងបុណ្យនេះ, មិនមែនតែខ្ញុំព្រះករុណា អាត្មាភាពម្នាក់ឯងទេត្រេកអរនេះ ទាំងលោកជាគ្រូពុទ្ធបរិស័ទក្នុងវត្តនេះទាំងមូលក៏ត្រេកអរដូចគ្នា, សូម្បីតែសាលាបុណ្យដែលជាវត្ថុមិនមានវិញ្ញាណ ក៏ប្រដាប់ខ្លួនដោយទង់ជាដើម ទទួលអំណរលោកក្នុងពេលនេះដែរ ។ ខ្ញុំព្រះករុណា អាត្មាភាពបានឃើញធម៌ថាមនុស្សសត្វក្នុងលោកនេះតែងជ្រកនៅក្រោមម្លប់ ៤ ប្រការ គឺ:

១ – រុក្ខឆាយា ម្លប់ឈើនានាដែលមានមែកត្រសុំត្រសាយសាខា នៅវេលាក្តៅមនុស្សសត្វដើរចូលទៅជ្រក ក៏ឈើនោះឲ្យជ្រកបានទូទៅឥត

វេសមុខ, ហើយអាចបាំងកំដៅថ្ងៃឲ្យអ្នកដេក បានសុខកាយសប្បាយចិត្តឥតមានប្រែប្រួល; ២– មាតាញាតិឆាយា ម្លប់មាតាបិតាជីដូនជីតាញាតិសាលោហិត អាចបាំងបិទកំដៅឲ្យដេកនៅបានតែត្រឹមកូនចៅចៅពង្សវង្សត្រកូលរបស់ខ្លួន, ៣– អាចរិយឆាយា ម្លប់គ្រូអាចារ្យក៏អាចការពារបិទបាំងបានតែត្រឹមសិស្សានុសិស្សរបស់ខ្លួនប៉ុណ្ណោះ មិនទូទៅដល់សិស្សគ្រូដទៃឡើយ, ៤– ពុទ្ធឆាយា ម្លប់ព្រះពុទ្ធសាសនាជាម្លប់ធំទូលាយក្រៃលែង តាមតែមនុស្សបែបណាជាតិណា ស្វែងមកពីទិសណាទីណាក៏ដោយ តែចូលមកដេកហើយ ម្លប់ព្រះពុទ្ធសាសនាក៏អាចបិទបាំងការពារកំដៅគឺភ្លើងទុក្ខភ្លើងកិលេស ដែលឆាបឆេះសព្វសត្វចូលដេកឲ្យត្រជាក់បានគ្រប់ៗគ្នា ។

ម្លប់ទាំង ៤ ប្រការដូចជាមកនេះឈ្មោះថាបានធ្វើឧបការគុណមុនលើមនុស្សអ្នកចូលដេក, ហេតុនេះអ្នកដេកត្រូវដឹងគុណ ត្រូវធ្វើតបឧបការគុណវិញ; បើដេកនៅក្រោមដើមឈើណា បុរាណថាមិនត្រូវស្មោះសម្បកកាប់មែកហែកបណ្តូលឈើនោះឡើយ; បើម្លប់មាតាបិតាជីដូនជីតាញាតិសាលោហិតវិញ ក៏កូនចៅអ្នកដេក ត្រូវគោរពកោតខ្លាចលោក ហើយប្រតិបត្តិលោកដោយជូនអាហារបាយទឹកនំចំណីនឹងគ្រឿងស្លៀកពាក់ជាដើម; បើម្លប់គ្រូអាចារ្យ សិស្សអ្នកដេក ត្រូវគោរពកោតខ្លាច ត្រូវប្រតិបត្តិលោក ដោយធ្វើកិច្ចវត្តផ្សេងៗ មានអាចារិយវត្តជាដើម, បើម្លប់ព្រះពុទ្ធសាសនាវិញ ពួកពុទ្ធបរិស័ទត្រូវគោរពកោតខ្លាចប្រតិបត្តិឲ្យត្រូវតាមគារវធម៌ ៧ ប្រការ មានពុទ្ធគារវតាជាដើម ។

ដោយហេតុនេះខ្ញុំព្រះករុណា សូមឱកាសរៀបរាប់ប្រវត្តិឧបការគុណ នៃត្រៃបុគ្គលរបស់ខ្ញុំ ៗ ប្រគេន - ជូនស្តាប់ឲ្យឃើញជាក់ស្តែងតទៅ

១ – លោកស្ងួ-យ៉ិន ជាមាតាគឺញោមស្រីខ្ញុំ លោកមានចិត្តអាណិតអាសូរចិញ្ចឹមបីបាច់ថែរក្សាស្នេហាស្រឡាញ់ថ្និតថ្នមខ្ញុំ ក្នុងគ្រួសារនេះជាងគេទាំងអស់ ចាប់តាំងពីខ្ញុំដេកនៅក្រោមម្លប់លោកគឺតាំងពីខ្ញុំដេកនៅក្នុងផ្ទៃលោកដរាបរៀងមក ៗ

២ – លោកព្រះសម្ភារពេជ្រ ហាស់ · មាស ជាបិតាគឺជាញោមប្រុសខ្ញុំ លោកបានចិញ្ចឹមបីបាច់ថែរក្សាខ្ញុំដោយថ្និតថ្នមលោកបានទាំងបង្រៀនវិជ្ជាអក្សរសាស្ត្រ និងលេខដល់ខ្ញុំដោយទឹកចិត្តអាណិតអាសូរប្រកបដោយព្រហ្មវិហារ ដរាបដល់ខ្ញុំបានចេះដឹងវិជ្ជាប្រើការធ្វើជាស្មៀនកត់ត្រាដោយលេខនិងអក្សរបាន លោកឥតដែលមានដេរស្តីឬវាយទះតប់ ឬកំហុទះបង្អាប់ដល់ខ្ញុំម្តងឡើយ; លោកមាតាលោកនិងបិតាទាំងពីរនេះ ចាប់តាំងពីខ្ញុំមកដេកនៅក្រោមម្លប់លោក ៗ ឲ្យសេចក្តីសុខដល់ខ្ញុំរៀងមកដរាបដល់ថ្ងៃលោកទទួលមរណភាពទៅ ៗ

ឯខ្លួនខ្ញុំជាកូនវិញ ចាប់តាំងពីថ្ងៃដឹងក្តីរហូតមក មិនដែលធ្វើឲ្យឃើសឃ្លងហ្មងគ្នងដល់ចិត្តលោក តែងខំជួយធ្វើការងារ និងចិញ្ចឹមបីបាច់ថែរក្សាតបឧបការគុណលោកទាំងពីរវិញ ដរាបដល់លោកចាស់ជរានៅវេលាមានជម្ងឺម្តងៗ ខ្ញុំបានរកថ្នាំនិងគ្រូពេទ្យមកជួយព្យាបាលពេគលោកលុះដល់លោកទទួលមរណៈទៅ ៗ ញោមស្រីជន្មាយុ ៨៥ ឆ្នាំ អនិច្ចកម្មក្នុងឆ្នាំជូតទោស័ក ព.ស. ២៤៩១ បើរាប់មកដល់ ព.ស. ២៤៩៧

នេះលោកអនិច្ចកម្ម៧ឆ្នាំហើយ; ញោមប្រុសជន្មាយុ ៨២ ឆ្នាំ អនិច្ចកម្ម ក្នុងឆ្នាំថោះបញ្ចស័ក ព. ស. ២៤៨១ ហើយមកដល់ ព. ស. ២៤៩៧ នេះលោកទទួលអនិច្ចកម្មទៅ ១៦ ឆ្នាំហើយ; កាលលោកទាំងពីររស់នៅឡើយ ខ្ញុំបានឧបត្ថម្ភលោក ឲ្យលោកស្ថិតនៅក្នុងសីលធម៌និងសមាធិជំមាំមួន លោកបានធ្វើខ្លួនលោកឲ្យជាទីពឹងខ្លួនបានក្នុងសីលសមាធិធម៌ ៗ

ខ្ញុំតែងទំនុកបំរុងផ្គត់ផ្គង់លោកដោយកិច្ចគ្រប់យ៉ាង មានជូនបាយទឹកនំចំណីជាដើម លុះដល់លោកមរណភាពទៅ ខ្ញុំបានរៀបចំធ្វើបុណ្យរំលាយសពលោកទាំងពីរជាឧឡារិក ជំសមគួរតាមឋានៈរបស់លោក ដែលខ្ញុំជាកូនត្រូវធ្វើដោយសេចក្តីគោរព ក្នុងទីបំផុតជីវិតរបស់លោកទាំងពីរនោះៗ ខ្ញុំបានកសាងចេតិយយកអដ្ឋិធាតុរបស់លោកមកធ្វើបុណ្យ ហើយបញ្ចុះទុកជាអនុស្សាវរីយ៍ក្នុងទីវត្តនេះ ខ្ញុំតែងនាំក្រុមញាតិធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសផលជូនរឿយៗរាល់ៗឆ្នាំ ៗ

៣ — ឯព្រះតេជព្រះគុណ ព្រះសព ព្រះពោធិវង្ស ទេព លោកជាគ្រូឧបជ្ឈាយ៍របស់ខ្ញុំ ជាប់តាំងពីសាមណេរមក ដរាបដល់ឧបសម្បទាជាភិក្ខុ, ហើយព្រះអង្គលោកជាគ្រូកម្មដ្ឋានាចារ្យធំមួយក្នុងកម្ពុជប្រទេសនេះ, ខ្ញុំបានរៀនសមថកម្មដ្ឋានអំពីលោកៗ បានបង្រៀនខ្ញុំឲ្យបានចេះដឹងដរាបដល់ធ្វើជាគ្រូបង្រៀនគេទៀតបាន លោកតែងរំលឹកដាស់តឿនខ្ញុំឲ្យធ្វើល្អ ឲ្យបានត្រឹមត្រូវតាមផ្លូវសីលធម៌ ដោយទឹកព្រះទ័យប្រកបដោយមេត្តា ឥតដែលមានដេរស្តីបន្ទោសថាអ្វីដល់ខ្ញុំឡើយ, មិនតែ

ប៉ុណ្ណោះបានតាំងឲ្យខ្ញុំមានសមណស័ក្តិ ជាទីព្រះសមុហ៍ពោធិបញ្ញា ភ្ជាប់តាមដំណែងសមណស័ក្តិរបស់លោក ។

ខ្លួនខ្ញុំជាសិស្សតែងតែធ្វើកិច្ចវត្តនានាដល់លោក មានគក់ច្របាច់ជាប្រក្រតី និងកិច្ចវត្តដទៃៗ ខ្ញុំគោរពប្រតិបត្តិលោក ឥតដែលមានឲ្យឃ្នើសឃ្នងព្រះទ័យឡើយ ខ្ញុំជាសទ្ធិវិហារិករបស់លោកជាសិស្សផ្ទាល់ព្រះអង្គបម្រើលោក គ្រប់កិច្ចការដរាបដល់លោកចាស់ជរាជន្មាយុ ៩៥ ឆ្នាំ ក៏ចាប់មានអាពាធជាទម្ងន់ ខ្ញុំបានចាត់ការរកថ្នាំ រកគ្រូពេទ្យខ្មែរ-បារាំងមកព្យាបាលរោគ តែព្រះអង្គលោកពុំព្រមឲ្យពេទ្យមើលសោះឡើយ ឱសថក៏លោកមិនព្រមឆាន់ផង, ក្នុងរវាង ១០ ថ្ងៃប៉ុណ្ណោះ ក៏លោកទទួលអនិច្ចធម្មទៅ ដោយរោគជរា ក្នុងជន្មាយុ ៩៥ ឆ្នាំ លោកអនិច្ចធម្មក្នុងឆ្នាំមមី ឯកស័ក ព. ស. ២៤៦២ បើរាប់ពីគ្រានោះមកដល់ ព. ស. ២៤៩៧ នេះ ៣៥ ឆ្នាំហើយ; ខ្ញុំក៏ខំចាត់ការធ្វើបុណ្យបូជាសពលោកជាមួយនឹងសិស្សានុសិស្ស ទាំងគ្រហស្ថទាំងបព្វជិតយ៉ាងធំអស្ចារ្យជាឱឡារិក ឲ្យបានសមតាមឋានៈរបស់លោក រួចហើយរើសអដ្ឋិធាតុកសាងព្រះចេតិយធ្វើបុណ្យអភិសេកព្រះពុទ្ធរូប បញ្ចុះអដ្ឋិធាតុទុកជាអនុស្សាវរីយ៍ ក្នុងទីចេតិយនៅព្រះលានមុខព្រះវិហារវត្តពិកទូរង្សីនេះ ដរាបដល់សព្វថ្ងៃ; ខ្ញុំមានចិត្តចាំឧបការគុណលោកជាបុព្វបុរសទាំងបីឥតភ្លេច បីដូចជាគេធ្លាក់ភ្ជាប់ទុកក្នុងហ្ឫទ័យ ទើបផ្ដើមធ្វើបុណ្យរំលឹកគុណលោក ក្នុងគ្រានេះជាឱឡារិក; ក្នុងពេលនេះ ខ្ញុំសូមរំលឹកអស់លោកជាពុទ្ធបរិស័ទទាំងឡាយសូមតាំងព្រះទ័យ សូមតាំងចិត្តប្រកបដោយ

មេត្តាការុញ្ញភាព ហើយសម្លឹងមើលទៅឆាយារូបទាំង ៤ ដែលតាំងទុកពីមុខនោះ សម្រឹងជញ្ជឹងព្រះត្រៃលក្ខណ៍ សម្រាកស្ងៀមចំនួន ១ នាទី តាំងចិត្តផ្សាយឧត្តមផលដល់លោកដោយមនោសម្ពស្សជា គ្រប់ៗគ្នា ។ (ឈប់សម្រាក ១ នាទី បែរមុខចំពោះឆាយារូបទាំង ៤) ។

ញោមទាំងពីរ! ព្រះតេជព្រះគុណព្រះសព! ខ្ញុំព្រះករុណាអាត្មាភាព ជាកូនមានដួងចិត្តមិនទាក់ឃើញច្បាស់នូវឧបការគុណលោកថ្មីៗ ជាប់នៅក្នុងចិត្តជានិច្ច ឥតបាត់សោះឡើយ ។

ពិតមែនតែប្រញោម រូបព្រះតេជព្រះគុណរលាយបាត់ទៅ តែអំពើល្អដែលបានកសាងហើយនោះ នៅជាប់បីដូចជាគេឆ្លាក់ទុកក្នុងដួងហឫទ័យនៃខ្ញុំព្រះករុណា អាត្មាភាព ឥតបាត់បន្តិចបន្តួចឡើយ ។

សូមញោម សូមព្រះតេជព្រះគុណជ្រាបថាក្នុងថ្ងៃ ១២-១៣ កើតខែអស្សុជនេះកូនបានធ្វើបុណ្យ ឧទ្ទិសផលជូន-ប្រគេនទៅ សូមអញ្ជើញ សូមនិមន្តមកទទួលយកភាគឧត្តមផលនេះ ដោយសេចក្តីសោមនស្សតាមសមគួរដល់សេចក្តីប្រាថ្នាកុំបីខានឡើយ ។

ម្យ៉ាងទៀត ក្រុមពុទ្ធបរិស័ទទាំងឡាយក្នុងវត្តពិកទូរង្សីនេះ សូមឧទ្ទិសកុសលក្នុងបុណ្យនេះអំពីចម្ងាយថ្វាយព្រះករុណា ជាព្រះប្រិយមហាក្សត្រិយ៍ ព្រមទាំងព្រះវររាជបិតា ព្រះវររាជជននីនាថ និងព្រះរាជវង្សានុវង្ស និងឯកឧត្តមរដ្ឋមន្ត្រីគ្រប់ក្រសួង ព្រមទាំងលោកអ្នករាជការគ្រប់ដំណែង ព្រមទាំងសហការីនៃអស់លោកនោះៗផង សូមឲ្យបានស្ថិតនៅក្នុងសេចក្តីសុខដែលកើតពីសុចរិតយុត្តិធម៌ ហើយឲ្យបាន

ប្រកបដោយយសស័ក្តិសិទ្ធិទ្ធិតេជៈ ឈ្នះអស់ពួកសត្រូវដែលស្ថិតនៅគ្រប់ទិសជាស្ថាពរតទៅ ។

នៅទីបំផុតនេះ ខ្ញុំព្រះករុណាអាត្មាភាពសូមអរគុណ សូមប្រគេន សូមជូនបុណ្យ ដល់អស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ដែលបានជួយខ្វល់ខ្វាយដោយកម្លាំងកាយនឹងកម្លាំងធនធាន ឲ្យបុណ្យនេះបានរុងរឿងឡើងដល់ប៉ុណ្ណោះ, សូមកុសលនេះជួយទ្រទ្រង់អស់លោកគ្រប់គ្នា ឲ្យបានជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចំរើន តាំងពីពេលនេះតទៅ ដរាបដល់បានសម្រេចមគ្គផលព្រះនិព្វានជាអវសានជាតិកុំបីឃ្លាតឡើយ ។

ពាក្យនេះបើអស់លោកយល់ព្រមជាសច្ចានុម័តហើយ គឺចូរឲ្យសទ្ទសញ្ញាថាសាធុ ៗ ព្រម ៗ គ្នាមកហោង ។

លើកទី ២ - ថ្ងៃអាទិត្យ ១៣ កើតខែឆ្នាំដដែល ពេលម៉ោង ៧·៣០ ព្រឹក ក្រុមនាក់ឧបត្ថម្ភជាច្រើនគ្នា បានរៀបចាត់ចែងយាគូតឹបបរប្រគេនព្រះសង្ឃចំនួន ៨ះ អង្គឆាន់ នឹងពួកអ្នកមកជួយបុណ្យទាំងអម្បាលម៉ាន ចំនួន ១៥០ នាក់ ពីសាត់តខ្វះខាតឡើយ ហើយដល់ទៅម្ហូបអាហារបិណ្ឌបាតក្នុងពេលថ្ងៃក៏មានលោកយាយ ៗ តា ៗ ជាកម្មដ្ឋានៈសិស្សានុសិស្ស នឹងក្រុមចំណុះជើងវត្តទាំងខ្មែរ, ចិន, យួន, ជួយផ្គត់ផ្គង់ជាច្រើនគ្នាទៀត, ឯខាងភេសជ្ជៈ គឺមានលោកអ្នកចាត់ចែងប្រគេនលោកគ្រប់ទាំងពីរថ្ងៃ គឺថ្ងៃ ១២-១៣ កើត ។

លុះដល់ម៉ោង ១១ ព្រឹក ព្រះសង្ឃដែលនិមន្តមកពីក្រៅ ២៧ វត្ត នឹងព្រះសង្ឃនៅក្នុងវត្តពិគន្ធវង្សរួមជា ៨០ អង្គ មានសម្តេចព្រះធម្មលិខិត

ឧត្តមប្រឹក្សា ល្វី-ឯម ចៅអធិការវត្តលង្កា ក្រុងភ្នំពេញជាប្រធាន, ចូលទៅគង់ក្នុងឧបដ្ឋានសាលា ជាសាលាធ្វើបុណ្យនោះសូត្រសត្តប្បករ-ណាភិធម្មចប់ហើយ បង្សុកូលរួចស្រេចពួកឧបាសកឧបាសិកាលើកចង្ហាន់មកវេរភត្តប្រគេនព្រះសង្ឃៗធ្វើភត្តានុមោទនាចប់ ក៏ឧទ្ទិសផ្សាយឧត្តមផលប្រគេន-ជូនទៅបុព្វការីបុគ្គល គឺដួងវិញ្ញាណក្ខន្ធនៃសពដែលបានរាប់នាមក្នុងសុន្ទរកថាខាងលើស្រាប់ លុះលោកធ្វើភត្តកិច្ចរួចស្រេចហើយ ប្រគេនទេយ្យទានមានចីវរជាដើម និងជូនដំណើរលោកដោយរថយន្តខ្លះ ដោយបវារណាថ្លៃយានជំនិះខ្លះ រួចកិច្ចមួយលើក លុះដល់ម៉ោង ១៥ ពួកឧបាសកឧបាសិកាមកជួបជុំនមស្សការហើយ ក៏និមន្តព្រះសង្ឃចូលទៅក្នុងឧបដ្ឋានសាលាជាសាលាបុណ្យ ហើយនិមន្តព្រះគ្រូមង្គលវង្ស អនុគណ ឯល ចៅអធិការវត្តរកាកោងក្នុង ស្រុកមុខកំពូល ខែត្រកណ្ដាល និងលោកព្រះគ្រូសង្ឃសុមេធ ឃង់-វ៉ាង វត្តឧណ្ណាលោម ក្រុងភ្នំពេញ ទេសនាសង្គាយនា ព្រះសង្ឃក្រៅពីនេះចំនួន ៥០ អង្គគង់ហត្ថបាស; លុះចប់ទេសនាហើយ ប្រគេនទេយ្យទានមានចីវរជាដើមដល់ព្រះសង្ឃគ្រប់ៗអង្គ ។

ឯឧបាសកឧបាសិកា និងក្រុមឧបត្ថម្ភវត្ត មានលោកអាចារ្យជាដើមក៏នាំគ្នាឧទ្ទិសផលរួចហើយ ទើបក្រុមរថយន្តជូនដំណើរ ក៏ចាត់ការជូនដំណើរលោកគ្រប់វត្ត ទៅដាក់តាមទីកន្លែងវត្តដែលលោកនៅ, សម្រេចកិច្ចបុណ្យត្រឹមប៉ុណ្ណេះ ។